# ផែនការ
# យុទ្ធសាស្ត្រ

BUILDING CAPACITY FOR CHANGE
វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ADVOCACY AND POLICY INSTITUTE

## ២០២៤
## ២០២៨






*“ប្រទេសកម្ពុជានឹងកាន់តែមានភាពសុខដុមរមនា មានបរិយាបន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ និងការគោរពគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។”*

ផែនការយុទ្ធសាស្ត្រ API

+855 23 213 486 apiinstitute.org apioffice@apiinstitute.org

# មាតិកា


១ បុព្វបទ ........ ០៤
២ វិទ្យាស្ថាន API ........ ០៥
៣ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ........ ០៦
៤ សមិទ្ធិផលនៃផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ ........ ០៦

៥ ការវិភាគបរិបទ ........ ០៩
៥.១ ប្រជាសាស្ត្រនៃប្រទេសកម្ពុជា ........ ០៩
៥.២ បរិបទនយោបាយ ........ ០៩
៥.៣ បរិបទសេដ្ឋកិច្ច ........ ១២
៥.៤ បរិបទសង្គម ........ ១៣
៥.៥ បរិបទច្បាប់ ........ ១៣
៥.៦ បរិបទបច្ចេកវិទ្យា ........ ១៤
៥.៧ បរិបទបរិស្ថាន ........ ១៤

៦ ទិសដៅយុទ្ធសាស្ត្រ ២០២៤-២៨ ........ ១៦
៦.១ ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ API ២០២៤-២៨ ........ ១៦
៦.២ បំណងប្រាថ្នារបស់ API ........ ១៧
៦.៣ គោលបំណង លទ្ធផល គោលដៅ និងសកម្មភាព ........ ១៨
គោលបំណងទី១ កែលម្អអភិបាលកិច្ចប្រជាធិបតេយ្យ និងគណនេយ្យភាព ........ ១៨
គោលបំណងទី២ ការតាត់តែង ការអនុវត្ត និងការត្រួតពិនិត្យច្បាប់ និងគោលនយោបាយសាធារណៈមានបរិយាបន្ន និងប្រជាធិបតេយ្យ។ ........ ២០
គោលបំណងទី៣ សិទ្ធិមនុស្សត្រូវបានគោរព ការពារ និងបំពេញបន្ថែម ........ ២២
គោលបំណងទី៤ API ត្រូវបានគ្រប់គ្រង និងចាត់ចែងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធផល។ ២៤

៧ ការតាមដានត្រួតពិនិត្យ ការគ្រប់គ្រងទិន្នន័យ និងការរាយការណ៍ ........ ២៦
៧.១ សូចនាករតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ........ ២៦
៧.២ ការគ្រប់គ្រងទិន្នន័យ ........ ២៦
៧.៣ ការធ្វើរបាយការណ៍ ........ ២៦

៨ ការវិភាគហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ........ ២៧

៩ ឧបសម្ព័ន្ធ ........ ២៨
ឧបសម្ព័ន្ធទី ១៖ ចំនួនអ្នកទទួលផលតាមភេទ និងគម្រោង ២០១៩-២៣ ........ ២៨
ឧបសម្ព័ន្ធទី ២៖ ក្របខណ្ឌ ពិនិត្យ និងវាយតម្លៃ ២០២៤-២៨ ........ ៣០
ឧបសម្ព័ន្ធទី ៣៖ ក្របខណ្ឌថវិកា ២០២៤-២៨ ........ ៣៩

១០ បញ្ជីឯកសារយោង ........ ៤៤

## បញ្ជីសំរាយអក្សរកាត់

| | |
|---|---|
| A2I | សិទ្ធិទទួលព័ត៌មាន |
| A2IWG | ក្រុមការងារសិទ្ធិទទួលព័ត៌មាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| BWG | ក្រុមការងារថវិកា |
| CBO(s) | អង្គការសហគមន៍មូលដ្ឋាន |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CSO(s) | អង្គការសង្គមស៊ីវិល |
| CPDD | អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍបែបប្រជាធិតេយ្យ |
| D&D | វិមជ្ឈការ និងសហវិមជ្ឈការ |
| DRWG | ក្រុមការងារសិទ្ធិឌីជីថល |
| KIIs | បទសម្ភាសន៍ជនបង្គោល |
| LGBTQI | ស្ត្រីស្រលាញ់ភេទដូចគ្នា បុរសស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ និងអ្នកមានភេទពីរ |
| NP- SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NCDD(S) | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន) |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| PESTLE | វិភាគនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកទេស ច្បាប់ និងបរិស្ថាន |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SA | គណនេយ្យភាពសង្គម |
| SAF | ក្របខ័ណ្ឌគណនេយ្យភាពសង្គម |
| SDG(s) | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SWOT | វិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាមកំហែង |
| SP4ALL | កិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា |
| UN | អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |

# វិទ្យាស្ថាន API សំដែងនូវអំណរគុណដល់ដៃគូ ដែលបានគាំទ្រក្នុងឆ្នាំ ២០១៩ - ២០២៣

**រួមមាន៖**

- អង្គការ Brot für die Welt (BftW),
- អង្គការ DanchurchAid (DCA),
- វិទ្យាស្ថាន East-West Management Institute, Inc. (EWMI),
- អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360),
- អង្គការ Nickol Global Solutions
- អង្គការ Oxfam នៅកម្ពុជា
- អង្គការផេក (PACT)កម្ពុជា
- ក្រសួងការបរទេសហូឡង់ តាមរយៈការផ្តល់ជំនួយឥតសំណងរបស់ Voice
- សហភាពអឺរ៉ុប (EU)
- ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (SIDA)
- កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP),
- មូលនិធិប្រជាធិបតេយ្យរបស់អង្គការសហប្រជាជាតិ (UNDEF),
- មូលនិធិអប់រំកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNICEF)
- ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID),
- ក្រសួងការបរទេសសហរដ្ឋអាមេរិក មូលនិធិ Wilde Ganzen (WG) ។

**ដៃគូរអនុវត្ត៖**

- សកម្មភាពសម្រាប់ការអភិវឌ្ឍសុខភាព (AHEAD),
- អង្គការ អេដ អេ អាកស្យុង (AeA)
- ក្រុមការងារប្រឆាំងអំពើពុករលួយ
- ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG),
- ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
- ក្រុមការងារថវិកា (BWG)
- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)
- អង្គការសហគមន៍មូលដ្ឋាន (CBO)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ (CDC)
- អង្គការអភិរក្សភាសាជនជាតិដើមភាគតិច (CIPL)
- អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- អង្គការអេពិកអាត (Apic Arts)
- អង្គការអភិវឌ្ឍន៍សុខភាពគ្រួសារ (FHD)
- សម្ព័ន្ធសុខភាពនិងអភិវឌ្ឍន៍ (HEAD)
- សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA )
- ជំនួយប្រកបដោយភាពច្នៃប្រឌិតចំពោះជំងឺ និងគ្រោះមហន្តរាយ (InSTEDD)
- អង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា (KWWA)
- សមាគមខ្មែរដើម្បីអភិវឌ្ឍន៍ជនបទកម្ពុជា (KAFDOC)
- សមាគមតន្ត្រីសំនៀងជនពិការ (MAPD)
- អង្គការភូមិខ្ញុំ (MVi)
- អ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
- វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)
- សមាគមមនុស្សចាស់ (OPA)
- មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញ (PPCIL)
- អង្គការព្រហ្មវិហារធម៌ (PVT)
- អង្គការជួយសង្គ្រោះប្រជាជនកម្ពុជាដែលងាយរងគ្រោះ (SVC)
- ក្រុមការងារកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា (SP4All)
- ក្រុមការងារបច្ចេកទេស និងគណៈកម្មាធិការដឹកនាំគណនេយ្យភាពសង្គម (ISAF PSC)
- សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្តពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ស្ពឺ កណ្តាល កំពង់ធំ
- ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)
- ក្រសួងសុខាភិបាល (MoH)
- ក្រសួងព័ត៌មាន
- ក្រសួងមហាផ្ទៃ (MoI)
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
- សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (NLCS)
- ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)

## ១ បុព្វបទ

ចាប់តាំងពីការបង្កើតដំបូងក្នុងឆ្នាំ ២០០៣ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) បានប្តេជ្ញាធានាការពារ លើកកម្ពស់ សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាស្របច្បាប់ ជាពិសេសក្រុមប្រជាពលរដ្ឋងាយរងគ្រោះ។ វាជាតួនាទីរបស់អង្គការ API ក្នុងការ "កសាងសមត្ថភាពសម្រាប់ការផ្លាស់ប្តូរ" ដើម្បីឱ្យប្រជាពលរដ្ឋមានលទ្ធភាពលើកឡើងពីកង្វល់ និងស្វែងរកដំណោះស្រាយបញ្ហារបស់ខ្លួន។

យើងកំពុងក្រឡេកមើលដោយការពេញចិត្ត លើការរៀបចំផែនការឆ្នាំ ២០១៩-២៣កន្លងមក ដែលបង្ហាញពីសមិទ្ធិផលដ៏ល្អ រួមទាំងគម្រោងជាច្រើនដែលបានសម្រេចលើសពីគោលដៅរំពឹងទុកកន្លងមក។

បើគ្មានការយកចិត្តទុកដាក់ពីបុគ្គលិករបស់យើងទេ លទ្ធផលល្អបែបនេះនឹងមិនអាចសម្រេចទៅរួចនោះទេ ហើយយើងសូមអរគុណសហសេវិកយើងទាំងអស់គ្នាសម្រាប់ការចូលរួមចំណែករបស់ពួកគេ។

យើងក៏សូមថ្លែងអំណរគុណចំពោះ ក្រុមប្រឹក្សាភិបាលរបស់យើងដែលបានរួមចំណែកពេលវេលាដ៏មានតម្លៃក្នុងការធ្វើឱ្យសមិទ្ធិផលដ៏ល្អទាំងនេះអាចសម្រេចទៅបាន។

អង្គការ API បានកំណត់នូវគោលដៅដូចខាងក្រោម៖ ត្រឹមចុងឆ្នាំ ២០២៨ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលនឹងមានសង្គមសុខដុមរមនា មានបរិយាបន្ន ការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ និងគោរពគោល-ការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ ផែនការយុទ្ធសាស្ត្រនេះគឺបង្ហាញផ្លូវដើម្បីសម្រេចគោលដៅនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី Kasumi Nakagawa និងលោក Michael Engquist តំណាងក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ការណែនាំសំខាន់ៗសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

យើងខ្ញុំទន្ទឹងរង់ចាំការបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូបច្ចុប្បន្នរបស់អង្គការ API និងស្វាគមន៍ដៃគូថ្មីក្នុងការចូលរួមចំណែកដើម្បីធ្វើឱ្យសង្គមកម្ពុជាកាន់តែមាន សុខដុមរមនា មានបរិយាបន្ន ការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ និងគោរពគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

ភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

**លោក ឡាំ សុជាតិ**

នាយកប្រតិបត្តិ

**សឿង ចន្ទ័តារា**

ប្រធានក្រុមប្រឹក្សាភិបាល

## ២ វិទ្យាស្ថាន API

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) គឺជាអង្គការឈានមុខគេរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យតស៊ូមតិ ឥទ្ធិពលគោលនយោបាយ ការចូលរួមរបស់ប្រជាពលរដ្ឋ និងអភិបាលកិច្ចល្អ។

### ចក្ខុវិស័យរបស់ API

ប្រទេសកម្ពុជាមាន សុខដុមរមនា ស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច អភិវឌ្ឍន៍ប្រកបដោយចីរភាព អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស ដែលធានាបាននូវអនាគតដ៏រុងរឿងសម្រាប់ទាំងអស់គ្នា។

### បេសកកម្ម

ដើម្បីបម្រើតម្រូវការអភិវឌ្ឍន៍សង្គម និងលទ្ធិប្រជាធិបតេយ្យរយៈពេលវែងរបស់ប្រទេសកម្ពុជា តាមរយៈការពង្រឹងសិទ្ធិអំណាចពលរដ្ឋក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋាភិបាល ក្នុងការការពារសិទ្ធិរបស់ពួកគេ។

### គោលដៅរបស់ API សម្រាប់ផែនការយុទ្ធសាស្ត្រនេះ

នៅឆ្នាំ ២០២៨ កម្ពុជានឹងក្លាយជាសង្គមមួយប្រកបដោយសុខដុមរមនា មានបរិយាបន្ន ការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ ការគោរពគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

### គុណតម្លៃរបស់ API

ខណៈពេលដែលវិទ្យាស្ថានប្រកាន់ខ្ជាប់យ៉ាងតឹងរឹងទៅនឹងតម្លៃស្នូលនៃតម្លាភាព គណនេយ្យភាព ឯករាជ្យភាព ភាពមិនលំអៀង និងវិជ្ជាជីវៈរបស់ខ្លួន រួមជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី និងសិទ្ធិមនុស្សស្មើគ្នា API បានទទួលការគោរព និងទំនុកចិត្តពីប្រជាជនកម្ពុជា និងអ្នកគាំទ្រអន្តរជាតិផងដែរ។

សកម្មភាពសំខាន់ៗរបស់ API រួមមានការសម្របសម្រួល និងការកសាងសមត្ថភាពដើម្បីពង្រឹងសិទ្ធិអំណាចពលរដ្ឋ ធ្វើការនៅកម្រិតមូលដ្ឋានដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីកង្វល់គោលនយោបាយ និងការភ្ជាប់សហគមន៍ទៅនឹងបណ្តាញសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាលផងដែរ។ ចាប់តាំងពីការបង្កើត API ក្នុងឆ្នាំ ២០០៣ វិទ្យាស្ថានបានចូលរួមក្នុងការតស៊ូមតិលើគោលនយោបាយដោយផ្ទាល់ ជាពិសេសទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន ជាឧទាហរណ៍ វិទ្យាស្ថានបានសម្រេចជោគជ័យផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងច្បាប់ចរាចរណ៍ថ្មីសម្រាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០១៥ និងលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០២៣។

នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៨ API បានទទួលជ័យលាភីរង្វាន់ "CARE Partnership Award 2018" ដែលផ្តល់ដោយវិទ្យាស្ថាន CARE Germany-Luxembourg ទទួលស្គាល់ស្នាដៃ API ជាដៃគូអន្តរជាតិដ៏ឆ្នើមសម្រាប់ការរួមចំណែកគាំទ្រសហគមន៍ជនបទ និងសកម្មជនសង្គមស៊ីវិលនៅកម្ពុជាក្នុងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម និងសម្រាប់បេសកកម្មរយៈពេលវែងរបស់ខ្លួនក្នុងការកសាងសមត្ថភាពតស៊ូមតិ។

API ក៏ទទួលបានពានរង្វាន់ដៃគូសមិទ្ធផលល្អបំផុតលំដាប់ទី ១" Best Performance Partner Award ក្នុងចំណោមដៃគូចំនួន ៤២ ពីទីភ្នាក់ងារ USAID/Pact ក្នុងឆ្នាំ ២០២៣ ស្តីពីរឿងរ៉ាវនៃការផ្លាស់ប្តូរដ៏សំខាន់បំផុតនៃសមត្ថភាពរៀបចំរបស់ API ក្នុងឆ្នាំ 2023។ API បានទទួលពានរង្វាន់ការអនុវត្តវិជ្ជាជីវៈល្អបំផុតនៃអង្គការក្រៅរដ្ឋាភិបាល NGO Good Professional Practice Award (NGO GPP) ក្នុងកំឡុងឆ្នាំ ២០២៣-២៥ សម្រាប់ការអនុលោមតាមច្បាប់ពេញលេញលើការគ្រប់គ្រងអង្គការ កម្មវិធី និងហិរញ្ញវត្ថុដែលមានពិន្ទុពេញ ១៣១/១៣៥ ក្នុងឆ្នាំ ២០២៣ ដែលនឹងមានសុពលភាពដល់ឆ្នាំ ២០២៥។

## ៣ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដោយប្រើប្រាស់វិធីសាស្ត្រ ការចូលរួម ប្រកបដោយបរិយាបន្ន ដើម្បីធានាថា ទស្សនៈ និងគំនិតរបស់ក្រុមការងារ API និងអ្នកពាក់ព័ន្ធសំខាន់ៗត្រូវបានទទួលដឹងឮ យកមកឆ្លុះបញ្ចាំង និងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ។ ក្រុមការងារបានប្រើប្រាស់ដំណើរការ និងប្រភពព័ត៌មានខាងក្រោម រួមមាន វិភាគនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកទេស ច្បាប់និងបរិស្ថាន (PESTLE) ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគម្រាមកំហែង (SWOT) និងការសម្ភាសន៍ជនបង្គោល (Klis)។




## ៤ សមិទ្ធិផលនៃផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩ - ២០២៣

ផែនការយុទ្ធសាស្ត្រ៥ឆ្នាំមុនរបស់ API (២០១៩-២០២៣) មានគោលបំណងសម្រេចលទ្ធផលសំខាន់ៗចំនួនបីគឺ៖ ឥទ្ធិពលគោលនយោបាយ ការចូលរួមរបស់ប្រជាពលរដ្ឋ សិទ្ធិទទួលបានព័ត៌មាន និងការបើកចំហព័ត៌មាន និងគោលបំណងទីបួនគឺបង្កើនសមត្ថភាព និងនិរន្តរភាពរបស់វិទ្យាស្ថាន API ។

**មេរៀនបានរៀនសូត្រ៖** វិធីសាស្ត្រតស៊ូមតិទន់ភ្លន់របស់ API មានប្រសិទ្ធភាព ដោយរក្សាទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល ដោយការចូលរួម និងគាំទ្រពួកគេក្នុងសកម្មភាពផ្សេងៗ។

### សម្រាប់គោលដៅយុទ្ធសាស្ត្រទី១៖ ឥទ្ធិពលគោលនយោបាយ

**ការតស៊ូមតិលើច្បាប់ និងគោលនយោបាយ៖** API បានតស៊ូមតិលើការតាក់តែង ឬការកែលម្អខ្លឹមសារនៃច្បាប់ គោលនយោបាយចំនួនប្រាំបី ដែលក្នុងនោះមានច្បាប់ទទួលព័ត៌មាន គឺជាចំណុចលេចធ្លោរបស់ API ។ គេរំពឹងថាច្បាប់នេះនឹងត្រូវបានទទួលយកដោយរាជរដ្ឋាភិបាល និង អនុម័តដោយរដ្ឋសភាក្នុងអំឡុងពេលធ្វើផែនការបច្ចុប្បន្ន។[i] ដូចគ្នានេះផងដែរ API បានតស៊ូមតិដោយជោគជ័យសម្រាប់ការប្រកាសឱ្យប្រើប្រាស់ច្បាប់លទ្ធកម្មសាធារណៈ និងការបង្កើនខ្ទង់ថវិកាជាក់លាក់នៅក្នុងច្បាប់ថវិកាជាតិប្រចាំឆ្នាំ (ដូចជាថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់ការអភិវឌ្ឍសេវាសង្គម)[ii] ។ (សមិទ្ធិផលសំខាន់មួយទៀតគឺការអនុម័តនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយរដ្ឋាភិបាល។ API ក៏បានធ្វើការតស៊ូមតិលើបញ្ហាជាច្រើនក្នុងវិស័យសិទ្ធិឌីជីថល ច្បាប់ថវិកាជាតិ ក្របខ័ណ្ឌគណនេយ្យភាពសង្គម និង កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

**ការពង្រឹងសិទ្ធិអំណាចពលរដ្ឋ និងអង្គការសហគមន៍មូលដ្ឋាន CBOs ដាក់ឥទ្ធិពលលើគោលនយោបាយ៖** នៅថ្នាក់ក្រោមជាតិ API បានជួយប្រជាពលរដ្ឋចំនួន ២៥៥០ នាក់ (ស្រី ៥៣៥ នាក់ ស្មើនឹង ១៨.៣%)[iii] ដើម្បីបញ្ចេញមតិ និង ផ្តល់ព័ត៌មានត្រឡប់ទៅការិយាល័យ ច្រកចេញចូលតែមួយ (OWSOs)។ ប្រជាពលរដ្ឋចំនួន ៤៥% ពេញចិត្តលើសេវាកម្មដែលរដ្ឋផ្តល់ឱ្យ ចំណែក ៤១% យល់ថាពួកគេអាចទទួលយកបាន និង ១៤%ផ្សេងទៀតជឿថាសេវាថ្លៃពេក។ API ក៏បានជួយប្រជាពលរដ្ឋលើកឡើងបញ្ហាកង្វល់ចំនួន ២៧៤ របស់ពួកគេចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះ ១៣១ បញ្ហា (៤៨%) ត្រូវបានដោះស្រាយ។

API ក៏បានបង្កើនសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន (CBOs)ចំនួន ១៧០ ក្នុងវិស័យតស៊ូមតិ ចំណេះដឹងផ្នែកច្បាប់ អភិបាលកិច្ចល្អ ការរៀបផែនការ និងថវិកាក្នុងមូលដ្ឋាន ។

**មេរៀនបានរៀនសូត្រ**[iv] មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងអ្នកមានកាតព្វកិច្ច(អ្នកផ្តល់សេវា)ផ្សេងទៀត ដើម្បីឱ្យពួកគេមានលទ្ធភាពឆ្លើយតបកាន់តែប្រសើរឡើង។ វាក៏ចាំបាច់ផងដែរក្នុងការលើកទឹកចិត្តម្ចាស់សិទ្ធិ (ប្រជាពលរដ្ឋ) ឱ្យបង្ហាញពីតម្រូវការ និងទាមទារសិទ្ធិរបស់ពួកគេ។ ការធ្វើឱ្យប្រសើរឡើងទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការជួយសម្រួលដល់ការកសាងទំនុកចិត្ត និងធ្វើឱ្យទំនាក់ទំនងការងារកាន់តែប្រសើរឡើង ដែលវាជាផ្នែកមួយដ៏សំខាន់នៃដំណើរការអភិវឌ្ឍក្នុងមូលដ្ឋាន ។

**ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដាក់ឥទ្ធិពលលើគោលនយោបាយ៖** ក្នុងអំឡុងពេលរៀបចំយុទ្ធសាស្ត្រលើកមុន API បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយបានបង្កើតឧបករណ៍បច្ចេកវិទ្យាចំនួនប្រាំពីរផ្សេងគ្នា (រួមមានប័ណ្ណពិន្ទុពលរដ្ឋចំនួន ១៩,៨០០ នាក់ (ក្នុងនោះ មានស្ត្រី ១២,៤៨៩នាក់ស្មើនឹង ៦៣%) និងមន្ត្រីរាជរដ្ឋាភិបាលចំនួន ៧,០០០ នាក់ដើម្បីកែលម្អសេវាការអប់រំសុខភាព និងរដ្ឋបាលនៅក្នុងឃុំចំនួន ២០០) និងបានផ្តល់ការសិក្សាអនឡាញក្នុងអំឡុងពេលនៃការរាតត្បាតជម្ងឺ Covid ១៩ ជាភាសាខ្មែរផងដែរ។

**មេរៀនបានរៀនសូត្រ៖** វាពិតជាមានប្រយោជន៍ក្នុងការខិតខំប្រើប្រាស់ជាប្រចាំនៃវេទិកាឌីជីថល ដោយសារវាផ្តល់នូវសក្តានុពលដ៏ធំធេងក្នុងការជំរុញគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ...

## សម្រាប់គោលដៅយុទ្ធសាស្ត្រទី ២៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

**ការពង្រឹងសិទ្ធិអំណាចពលរដ្ឋ៖** API បានធ្វើការជាមួយអង្គការសហគមន៍មូលដ្ឋាន CBOs និងយុវជន ចំនួន ៥៥៨០២ នាក់ (ស្ត្រី ២៥,២៨៩ នាក់ស្មើនឹង ៤៥.៣%) ក្នុងនោះមាន អង្គការសហគមន៍មូលដ្ឋាន ចំនួន៦ អង្គការក្រៅរាជរដ្ឋាភិបាលចំនួន ២៣ និង អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)[v] ៥៤៥នាក់ ដើម្បីទាមទារឱ្យមានគណនេយ្យភាព ការឆ្លើយតបនិងការសម្រេចចិត្តប្រកបដោយបរិយាបន្ន និងសេវាកម្មសាធារណៈ និងសកម្មភាពនានាដើម្បីកែលម្អការអនុវត្តគោលនយោបាយថ្នាក់ក្រោមជាតិ។ សមិទ្ធផលដែលបានមកពីការត្រួតពិនិត្យសេវារដ្ឋបាលថ្នាក់ក្រោមជាតិដោយអ្នកទទួលបាននូវសិទ្ធិអំណាច ចំនួននៃការពេញចិត្តរបស់ប្រជាពលរដ្ឋ មានជនជាតិភាគតិច ជនមានពិការភាព និងយុវជនសម្រាប់ការអនុវត្តរបស់រដ្ឋាភិបាលបានកើនឡើង នៅចន្លោះឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១ ។[vi] គួរកត់សម្គាល់ថាអ្នកឆ្លើយតប៨០%[vii] បានសង្កេតឃើញមានភាពប្រសើរឡើងលើគុណភាពនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**រដ្ឋបាលថ្នាក់ក្រោមជាតិដែលគិតគូរពីតម្រូវការ និងអាទិភាពនៃសហគមន៍របស់ពួកគេ៖** ក្នុងកំឡុងឆ្នាំ ២០១៩-២០២៣ API បានធ្វើការនៅក្នុងខេត្តចំនួន ១៩ ក្នុងចំណោម ២៤ ខេត្ត/ក្រុងរបស់ប្រទេសកម្ពុជា ដែលគ្របដណ្តប់ស្រុក/ក្រុងចំនួន ៥០ ដែលក្នុងនោះមានរាជធានីភ្នំពេញផងដែរ។ លទ្ធផលនេះបានធ្វើឱ្យសំឡេងរបស់ប្រជាពលរដ្ឋត្រូវបានយកមកពិចារណានៅក្នុងឃុំសង្កាត់ចំនួន ៦០៥ និង ក្រុងស្រុកចំនួន ៩១ (៨៥% នៃរដ្ឋបាលថ្នាក់ក្រោមជាតិ) ដែលពាក់ព័ន្ធនឹងមណ្ឌលសុខភាពចំនួន ១១៦ និងសាលាបឋមសិក្សាចំនួន ៧៩៥ ។

**មេរៀនបានរៀនសូត្រ៖** ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាគឺទាមទារការតស៊ូមតិជាក់លាក់ដើម្បីអាចចូលរួមបាន ដោយសារតែមានវប្បធម៌រក្សាការសម្ងាត់ឬមិនបើកចំហ។ បើទោះបីជាកិច្ចប្រជុំក្រុមប្រឹក្សាបើកជាសាធារណៈក៏ដោយ ក៏ក្រុមប្រឹក្សាតែងតែអញ្ជើញមនុស្សតែពីរបីនាក់ប៉ុណ្ណោះឱ្យចូលរួម។ ដោយកន្លែងប្រជុំរបស់ក្រុមប្រឹក្សា មានកន្លែងតិចតួចប៉ុណ្ណោះសម្រាប់ប្រជាពលរដ្ឋជួបជុំ។

## សម្រាប់គោលដៅយុទ្ធសាស្ត្រ ៣៖ សិទ្ធិទទួលបានព័ត៌មាន

**បង្កើនចំណេះដឹងអំពីសិទ្ធិទទួលបានព័ត៌មាន៖** API បានពង្រឹងសិទ្ធិអំណាចពលរដ្ឋជិតពីរលាននាក់ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេដើម្បីទទួលបានព័ត៌មានសាធារណៈ។ ការឆ្លើយតបពីផ្នែកផ្គត់ផ្គង់មានលក្ខណៈវិជ្ជមានលើស្ថាប័នសាធារណៈចំនួន ៦៧៨ ដែលបង្ហាញព័ត៌មានថវិកា និងស្តង់ដារសេវាសាធារណៈ។ រដ្ឋបាលខណ្ឌ និងក្រុងទាំង ៤០ ដែលត្រូវជាក្រុមគោលដៅរបស់គម្រោងរបស់ API បានបង្ហាញ តម្លាភាពកាន់តែច្រើនតាមរយៈការផ្តល់ពីព័ត៌មានថវិកា។

**មេរៀនបានរៀនសូត្រ៖** ការធ្វើការជាមួយយុវជនអាចជួយកៀរគរការគាំទ្រសម្រាប់ការផ្សព្វផ្សាយចំណេះដឹង។ យុវជន និងអង្គការសង្គមស៊ីវិលបានចូលរួមក្នុងវេទិកាពិគ្រោះយោបល់ ដែលជំរុញការចែករំលែកព័ត៌មានក្នុងមូលដ្ឋាន។

## សម្រាប់គោលដៅយុទ្ធសាស្ត្រទី ៤៖ អភិវឌ្ឍសមត្ថភាពស្ថាប័នរបស់ API

**សមត្ថភាពកៀរគរថវិកាត្រូវបានពង្រឹង៖** API បានធ្វើឱ្យមានការកើនឡើងដល់ទៅ ៦០% នៃថវិកាចំណូល និងចំណាយប្រចាំឆ្នាំរបស់ខ្លួន ទ្វេដងលើសធ្វើផែនការ។ បុគ្គលិកកើនពី ១៧ នាក់ (ស្រី ៥ នាក់ ២៩.៤%) ក្នុងឆ្នាំ ២០១៩ ដល់ ៣៨ នាក់ (ស្រី ១៧ នាក់ ៤៤.៧%) ក្នុងឆ្នាំ ២០២៣ ។

នៅឆ្នាំ ២០២៣ ទិន្នន័យមូលដ្ឋានតាមប្រព័ន្ធអនឡាញផ្នែកពិនិត្យតាមដាន និងវាយតម្លៃ API's Monitoring, Evaluation and Learning (MEAL) បានដាក់ឱ្យប្រើប្រាស់។ តាមនីតិវិធីស្តង់ដា API បានវាយតម្លៃសមិទ្ធផល និងបញ្ហាប្រឈមនៃគម្រោងទាំង ២០ ដែលបានបញ្ចប់ក្នុងកំឡុងឆ្នាំ ២០១៩-២៣ (សូមមើលឧបសម្ព័ន្ធទី ១) ដើម្បីរួមចំណែកដល់ការបង្កើតសកម្មភាពថ្មី និងបង្កើនសមត្ថភាពក្រុមការងារ API ។

**ធ្វើឱ្យប្រសើរឡើងក្នុងតួនាទីដឹកនាំនិងសម្របសម្រួលក្រុមការងារនៃអង្គការក្រៅរដ្ឋាភិបាល៖** API បានធ្វើជាប្រធាននៃក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) តាំងពីឆ្នាំ ២០០៧ ដែលបានរួមចំណែកយ៉ាងច្រើន ហើយក៏ជាសមាជិកសកម្មនៃក្រុមការងារសិទ្ធិឌីជីថល ក្រុមការងារកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា និងក្រុមការងារថវិកា និងក្រុមការងារផ្សេងៗទៀត។ API ក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធភាពជាដៃគូក្នុងការអភិវឌ្ឍប្រជាធិប-តេយ្យ(CPDD) ហើយបានក្លាយជាអង្គការសមាជិកភាពនៃអង្គការក្រៅរាជរដ្ឋាភិបាលនៅឆ្នាំ ២០១៧ (កើតចេញពីក្រុមការងារភាពជាដៃគូរសម្រាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ)។ សកម្មភាពទាំងនេះបង្ហាញថា API ដើរតួនាទីសម្របសម្រួលដ៏សំខាន់នៅក្នុងវិស័យអង្គការមិនមែនរាជរដ្ឋាភិបាល (WGPD)។ ក្រុមការងារទាំងនេះក៏ផ្តល់ឱ្យ API មានបណ្តាញដៃគូសហការយ៉ាងទូលំទូលាយ បានរួមចំណែកជោគជ័យលើសមិទ្ធផលជាច្រើន។

**ការទទួលបានវិញ្ញាបនប័ត្រការអនុវត្តវិជ្ជាជីវៈ៖** គុណភាពនៃអភិបាលកិច្ច ការគ្រប់គ្រងធនធាន និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងស្ថាបន័របស់ API ទទួលបាននូវវិញ្ញាបនប័ត្រអភិបាលកិច្ចល្អ និងការអនុវត្តវិជ្ជាជីវៈ ផ្តល់ដោយគណៈកម្មាធិការសម្របសម្រួលកម្ពុជា (CCC) ក្នុងឆ្នាំ ២០១៩ និង ២០២៣។

ដៃគូអភិវឌ្ឍន៍ចាត់ទុក API ជាអង្គការដែលប្រើប្រាស់បណ្តាញធំទូលាយ គ្រប់គ្រងបានល្អ និងអាចរក្សាទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធគ្រប់ប្រភេទ រួមទាំងខាងក្រសួងរដ្ឋាភិបាល មន្ត្រីរាជរដ្ឋបាលថ្នាក់ក្រោមជាតិប្រជាពលរដ្ឋសហគមន៍ និង អង្គការសង្គមស៊ីវិល CSO ផ្សេងទៀត។

# ៥ ការវិភាគបរិបទ

## ៥.១ ប្រជាសាស្ត្រនៃប្រទេសកម្ពុជា

ប្រជាជនកម្ពុជាសរុបមានប្រមាណ ១៥,២៨ លាននាក់ក្នុងឆ្នាំ ២០១៩[viii] ហើយកើនឡើងដល់ ១៦,៩ លាននាក់នៅឆ្នាំ ២០២៣[ix] ដែលមានន័យថាមានអត្រាកំណើនប្រចាំឆ្នាំ ១,១ ភាគរយ។ យោងតាមជំរឿនទូទៅនៃប្រជាជនកម្ពុជា (GPCC) (2022) ប្រហែល ៨៩% នៃចំនួនប្រជាជនដែលមានអាយុធ្វើការ (១៥-៥៩ ឆ្នាំ) រួមមានស្ត្រី ៤,២២៩,៩២៧ នាក់ (៤៩%) និង ០.៦៥% មានអាយុក្រោម ១៥ ឆ្នាំ មានស្ត្រី ២២,៤៥៧ នាក់ (០.២៦%)[x] ជាកម្មករ ៩៣% ត្រូវបានជួលក្នុងវិស័យការងារក្រៅប្រព័ន្ធ នៅឆ្នាំ ២០២០។[xi]

## ៥.២ បរិបទនយោបាយ

### ៥.២.១. ការវិវត្តនយោបាយថ្មីៗ

គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់អតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដឹកនាំការអភិវឌ្ឍនយោបាយប្រទេសតាំងពីឆ្នាំ ១៩៧៩។ សេរីភាពបានថយចុះចាប់តាំងពីគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ) ត្រូវបានរំលាយនៅឆ្នាំ ២០១៧ ។ បើទោះជាទទួលបានជោគជ័យក្នុងការរក្សាសន្តិភាព និងស្ថេរភាពក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះក្តី ក៏សេរីភាពផ្នែកនយោបាយបានចុះថយជាលំដាប់ ចាប់តាំងពីមានការរំលាយគណៈបក្សប្រឆាំង (គណៈបក្សសង្គ្រោះជាតិ CNRP) ក្នុងឆ្នាំ ២០១៧ កន្លងមក។[xii]

លទ្ធផលពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនាពេលថ្មីៗនេះ បង្ហាញថា នៅក្នុងការបោះឆ្នោតឃុំសង្កាត់ ខែមិថុនា ឆ្នាំ ២០២២ គណបក្សប្រជាជនកម្ពុជាទទួលបានសន្លឹកឆ្នោត ៨០% ខណៈដែលគណបក្សភ្លើងទៀន ឈ្នះបាន ១៨% ។[xiii] សម្រាប់ការបោះឆ្នោតសកលខែកក្កដា ឆ្នាំ ២០២៣ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន ១២០ ក្នុងចំណោមអាសនៈទាំងអស់ ១២៥ នៃរដ្ឋសភា។ បេក្ខជនឈរឈ្មោះសភាគណបក្សភ្លើងទៀន ត្រូវបានដកសិទ្ធិ[xiv] បន្តដោយការតែងតាំងនាយករដ្ឋមន្ត្រីថ្មី សម្តេច ហ៊ុន ម៉ាណែត ដែលបានក្លាយជាអនុប្រធានគណបក្សប្រជាជនកម្ពុជា។ នាយករដ្ឋមន្ត្រីថ្មីបានចាប់ផ្តើមកាន់តំណែងនៅខែកក្កដាឆ្នាំ ២០២៣ ដោយបានចេញនូវគោលនយោបាយថ្មីមួយ ចំនួនរួមទាំងយុទ្ធសាស្ត្របញ្ចកោណ ដែលផ្តោតលើប្រាំចំណុចរួមគ្នាធានានិរន្តរភាពនៃការអភិវឌ្ឍរបស់កម្ពុជា។[xv]

នៅចន្លោះឆ្នាំ ២០០០ និង ២០២២ សូចនាករអភិបាលកិច្ចទូទាំងពិភពលោក[xvi] របស់ធនាគារពិភពលោក (WB) បានផ្តល់ពិន្ទុដល់ប្រទេសកម្ពុជាជាមួយនឹងការកើនឡើងនៃស្ថេរភាពនយោបាយ ប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងនីតិរដ្ឋ ខណៈដែលមានការថយចុះលើការបញ្ចេញមតិ គណនេយ្យភាព គុណភាពបទប្បញ្ញត្តិ និង អំពើពុករលួយ។[xvii]

នៅលើឆាកអន្តរជាតិនៅ កម្ពុជាធ្វើជាប្រធានសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នាឆ្នាំ ២០២២ និងទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាននៅខែវិច្ឆិកា ឆ្នាំ ២០២២ ដោយជោគជ័យ។ កម្ពុជាក៏បានដើរតួនាទីក្នុងការអភិវឌ្ឍកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់ក្នុងខែមករា ឆ្នាំ ២០២២។

### ៥.២.២. ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ

អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) ត្រូវបានពង្រឹងតាមរយៈដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់រាជរដ្ឋាភិបាល ដោយមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិ។[xviii] រាជរដ្ឋាភិបាលក៏ទទួលស្គាល់ផងដែរថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់ដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ច-សង្គមរបស់ខ្លួន។[xix]

មានវឌ្ឍនភាពល្អខ្លះហើយ ទាក់ទងនឹងការកែលម្អអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងអំឡុងពេលកម្មវិធីជាតិលើកទី១ របស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD, ២០១០-២០២០) មុខងារសំខាន់ៗចំនួន ៥៥ ត្រូវបានផ្ទេរទៅថ្នាក់ស្រុក/ក្រុង (ដូចបានកំណត់ដោយអនុក្រឹត្យរបស់រដ្ឋាភិបាលលេខ ១៨២ ១៨៣ និង ១៨៤) រួមជាមួយនឹងបុគ្គលិកប្រមាណ ២ ម៉ឺននាក់ បានចូលរួមអនុវត្តមុខងារទាំងនោះ។ រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលខុសត្រូវគ្រប់គ្រងបុគ្គលិករបស់ខ្លួន និងបុគ្គលិកក្រសួងដែលកំពុងបំពេញមុខងារផងដែរ។[xx] ការផ្ទេរធនធានហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះដែរ។[xxi]

ទោះបីជាមានការរីកចម្រើនជាវិជ្ជមានរហូតមកដល់បច្ចុប្បន្នក៏ដោយ បញ្ហាប្រឈមផ្លូវច្បាប់ និងប្រតិបត្តិការមួយចំនួននៅតែកើតមានឡើង ដោយរួមមានគណនេយ្យភាព និងខ្សែបន្ទាត់រាយការណ៍ថ្មី។[xxii] ការអភិវឌ្ឍសមត្ថភាពគឺចាំបាច់ជាពិសេស ដើម្បីបង្កើនការយល់ដឹងដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពីមុខងារ និងទំនួលខុសត្រូវរបស់ពួកគេ ក្នុងនោះមាន(១) វិធីអនុវត្តក្នុងនាមជាស្ថាប័នរៀបចំគោលនយោបាយ គាំទ្រផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២) ធ្វើជាតំណាងប្រកបដោយប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង (៣) របៀបគ្រប់គ្រងសេវាសាធារណៈដែលគាំទ្រដោយថ្លៃសេវា (ឧ. ការគ្រប់គ្រងសំណល់រឹង)[xxiii]

ក្នុងឆ្នាំ ២០២១ រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជំហ៊ានទី២ (NP-SNDD-2) ដែលបានផ្តល់ការជំរុញបន្ថែមដល់ការកែលម្អការផ្តល់សេវាដល់ប្រជាពលរដ្ឋកម្ពុជា។[xxiv] តាមទស្សនៈរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NCDDS គេឃើញមានលំហសម្រាប់ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងសកម្មភាពអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ និងជួយប្រជាពលរដ្ឋឱ្យទាមទាររដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការអនុវត្តការងាររបស់ពួកគេ។[xxv]

### ៥.២.៣. ការយល់ដឹងមានកម្រិតរបស់ប្រជាពលរដ្ឋ អំពីអភិបាលកិច្ចល្អ

ចំណេះដឹងដែលទទួលបានមួយចំនួនពីគម្រោងជាច្រើនដែលអនុវត្តដោយ API ក្នុងពេលធ្វើផែនការមុនគឺ (១) មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ យល់ដឹងមិនពេញលេញអំពីមុខងារ និងសិទ្ធិរបស់ពលរដ្ឋក្នុងការសាកសួរ (២) ប្រជាពលរដ្ឋមានការយល់ដឹងតិចតួចពីមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមិនដឹងថាពួកគេអាចរំពឹងអ្វីខ្លះពីមន្ត្រីសាធារណៈ។

យោងតាមរបាយការណ៍ភាពជាដៃគូថវិកាអន្តរជាតិ (២០២១) ការយល់ដឹងមានកម្រិតរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ទាក់ទងនឹងសិទ្ធិពលរដ្ឋក្នុងការសាកសួរ កម្ពុជាទទួលបានពិន្ទុ ៣៣ លើ ១០០ លើតម្លាភាពថវិកា។[xxvi] ក្នុងរបាយការណ៍ដូចគ្នាកម្ពុជាទទួលបានពិន្ទុ 0 លើ ១០០ សម្រាប់ការចូលរួមជាសាធារណៈលើការអនុម័តថវិការបស់រដ្ឋាភិបាលថ្នាក់ជាតិ។ នៅថ្នាក់ក្រោមជាតិ អង្គការក្រៅរដ្ឋាភិបាលបានស្នើសុំឱ្យមានតម្លាភាពបន្ថែមទៀតលើការបែងចែកថវិកាឃុំ សង្កាត់ ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។[xxvii]

### ៥.២.៤. គណនេយ្យភាពរបស់អ្នកមានកាតព្វកិច្ចមានភាពប្រសើរឡើង

ដើម្បីមានអភិបាលកិច្ចល្អ មន្ត្រីសាធារណៈត្រូវមានតម្លាភាពជាចាំបាច់ចំពោះសកម្មភាព និងការសម្រេចចិត្ត ហើយត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ពួកគេនៅចំពោះមុខប្រជាពលរដ្ឋ។[xxviii]

ដូចគ្នានេះដែរការទទួលបានព័ត៌មានគឺជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យមន្ត្រីរាជរដ្ឋាភិបាលទទួលខុសត្រូវ និងលើកកម្ពស់តម្លាភាព។ ក្នុងអំឡុងពេល គណនេយ្យភាពសង្គម (ISAF) ដំណាក់កាល-១ API បានរួមចំណែកក្នុងការបង្កើនការផ្តល់ព័ត៌មាន ដែលនាំឱ្យកាន់តែមានតម្លាភាពក្នុងការសម្រេច

ចិត្ត និងការចំណាយរបស់ឃុំ សង្កាត់លើមណ្ឌលសុខភាព និងសាលារៀន។[xxix] ទោះបីជាយ៉ាងណាក៏ដោយ ភាពខ្វះចន្លោះក្នុងការយល់ដឹងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមកិច្ចប្រជុំដោយគ្មានការអញ្ជើញ[xxx] ជាចំណុចដែលប្រជាពលរដ្ឋអាចទាមទារឱ្យមន្ត្រីរាជរដ្ឋាភិបាលទទួលខុសត្រូវ។

### ៥.២.៥. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ច/ការចូលរួមរបស់ប្រជាពលរដ្ឋ

នៅប្រទេសកម្ពុជា លំហប្រជាធិបតេយ្យកាន់តែរួមតូច។ បុគ្គល និងគណបក្សនយោបាយ មិនសូវចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗ ដែលធ្វើឱ្យអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យស្ថិតក្នុងហានិភ័យ។[xxxi] អង្គការសិទ្ធិមនុស្សមួយចំនួនដែលធ្វើលើវិស័យតស៊ូមតិត្រូវបានកាត់បន្ថយ ហើយសកម្មជនមួយចំនួនត្រូវបានចាប់ខ្លួន ឬដាក់ពន្ធនាគារ។[xxxii]

### ៥.២.៦. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការតាក់តែងច្បាប់ និងគោលនយោបាយ

ដំណើរការតាក់តែងច្បាប់ និងគោលនយោបាយត្រូវបានគ្របដណ្ដប់ដោយមន្ត្រីដែលតែងតាំងដោយគណបក្សប្រជាជនកម្ពុជា CPP នៅក្នុងក្រសួងនានា ដែលមានការពិគ្រោះយោបល់ជាសាធារណៈតិចតួច[xxxiii] ។ មានការអញ្ជើញអង្គការសង្គមស៊ីវិល (CSOs) រួមទាំង API ឱ្យធ្វើអត្ថាធិប្បាយលើសេចក្ដីព្រាងច្បាប់ ប៉ុន្តែមតិរបស់ពួកយើងមិនត្រូវបានពិចារណាពេញលេញនោះទេ។ អាស្រ័យហេតុនេះ ឱកាសមានតិចតួចសម្រាប់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិអំពីផលប៉ះពាល់នៃគោលនយោបាយ និងច្បាប់មួយចំនួនលើពួកគេ។ មតិយោបល់របស់ក្រុមប្រជាពលរដ្ឋងាយរងគ្រោះក្នុងប្រអប់ខាងក្រោម ជារឿយៗមិនត្រូវបានគេយកទៅពិចារណាទេ ដោយសារពួកគេគ្មានលទ្ធភាពចូលរួមឬខ្វះមធ្យោបាយសម្រួលដើម្បីធ្វើការលើកឡើងពីកង្វល់របស់ពួកគេក្នុងដំណើរទាំងនោះ ដើម្បីឱ្យអ្នកបង្កើតគោលនយោបាយ ឬអ្នកបង្កើតច្បាប់ទទួលដឹងឮ។

**ក្រុមប្រជាពលរដ្ឋងាយរងគ្រោះបំផុតគឺ**

ក្រុមប្រជាពលរដ្ឋដែលមានភាពក្រីក្រខ្លាំង ក្រុមប្រជាពលរដ្ឋមានបំណុលច្រើន ជនជាតិដើមភាគតិច ជនមានពិការភាព កុមារក្រៅសាលា ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា ក្រុមស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងក្រុម Queer (LGBTIQ) ជនចំណាកស្រុក និងជនគ្មានប្រទេសស្នាក់នៅ។

### ៥.២.៧. អនុសាសន៍គោលនយោបាយដែលមានមូលដ្ឋានពីការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជា អនុសាសន៍គោលនយោបាយផ្អែកលើការស្រាវជ្រាវនៅមិនមានប្រើប្រាស់គ្រប់គ្រាន់នៅឡើយដោយសារមូលហេតុ (១) ធនធានហិរញ្ញវត្ថុមានកម្រិតដើម្បីបង្កើតគោលនយោបាយបែបនេះ និង (២) កង្វះអ្នកស្រាវជ្រាវដែលមានបទពិសោធន៍ក្នុងការនាំយកការវិភាគផ្អែកលើភស្តុតាងដើម្បីមានឥទ្ធិពលលើការបង្កើតគោលនយោបាយ។ ឧបសគ្គទាំងនេះរារាំងការសម្រេចបាននូវលទ្ធផលដែលកម្ពុជាចង់បានក្នុងការបង្កើតគោលនយ-បាយ និងធ្វើឱ្យការអភិវឌ្ឍប្រទេសទាំងមូលមានភាពយឺតយ៉ាវ។

គេសង្កេតឃើញមានលទ្ធផលវិជ្ជមាន ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះផងដែរ ដែលរាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការប្រើប្រាស់ទិន្នន័យ និងការបញ្ចូលភស្តុតាងនៃកិច្ចការស្រាវជ្រាវទៅក្នុងដំណើរបង្កើតគោលនយោបាយសាធារណៈ។[xxxiv] ចំណេះដឹងទទួលបានដោយការស្រាវជ្រាវមកពី (១) ក្រុម/អង្គភាពស្រាវជ្រាវរបស់រាជរដ្ឋាភិបាល (២) អ្នកជំនាញបច្ចេកទេសដៃគូអភិវឌ្ឍន៍ (៣) វិទ្យាស្ថានស្រាវជ្រាវ និងក្រុមអ្នកវិភាគ (៤) មជ្ឈ-មណ្ឌលស្រាវជ្រាវសាកលវិទ្យាល័យ (៥) ទីភ្នាក់ងារអង្គការសហប្រជាជាតិ (៦) អង្គការក្រៅរដ្ឋាភិបាល និង (៧) ក្រុមហ៊ុនប្រឹក្សា និងអ្នកប្រឹក្សាបុគ្គល។[xxxv] ផ្នែកនេះអាចដកចេញ ហើយបញ្ចូលការស្រាវជ្រាវ API ជំនួសវិញ។

### ៥.២.៨ សិទ្ធិមនុស្ស[xxxvi]

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ (UN) បានវិភាគស្ថានការណ៍កម្ពុជា ដោយផ្អែកលើចំណុចគោលចំនួន ២០ ហើយក្នុងចំណោមនោះ មានតែ ៥ ចំណុចប៉ុណ្ណោះ ដែលស្ថិតនៅលើគោលដៅ។[xxxvii] ចំណុចគោលដ៏សំខាន់បំផុតមួយក្នុងការវិភាគបង្ហាញឱ្យឃើញថា (១)ក្រុមអ្នកការពារសិទ្ធមនុស្ស ក្រុមអ្នកនយោបាយប្រឆាំង និងមេដឹកនាំសហជីពត្រូវបានឃុំខ្លួន (ដោយហេតុផលនយោបាយ); (២) ពហុបក្សកំពុងត្រូវបានបំបាត់។ (៣) មានការកាត់ក្ដីយ៉ាងតិចបួនករណី ខ្វះភស្តុតាងដែលអាចទុកចិត្តបាន និងគ្មានការគោរពការកាត់ក្ដីដោយយុត្តិធម៌ (៤) តុលាការមិនឯករាជ្យ (៥) មានការបាត់ខ្លួនដោយបង្ខំ។[xxxviii] មានក្ដីកង្វល់មួយទៀតគឺ សេរីភាពនៃការបញ្ចេញមតិ ដែលជាសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋត្រូវបានកាត់បន្ថយយ៉ាងខ្លាំង។[xxxix]

ប្រទេសកម្ពុជានៅតែឈរលើចំណាត់ថ្នាក់ទី ១៥០ ក្នុងចំណោម ១៨០ ប្រទេសលើសន្ទស្សន៍ ២០២ នៃការយល់ឃើញអំពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ។[xl] នៅមានវិសាលភាពធំសម្រាប់ការកែលម្អ រួមទាំងការអនុម័តច្បាប់សិទ្ធិទទួលព័ត៌មាន ការលើកកម្ពស់សិទ្ធិ ទាមទារឱ្យអ្នកកាន់កាប់អំណាច ទទួលខុសត្រូវ ការពង្រឹងការត្រួតពិនិត្យស្ថាប័នលើការប្រើប្រាស់អំណាច។[xli]

## ៥.៣ បរិបទសេដ្ឋកិច្ច

### ៥.៣.១. កំណើនសេដ្ឋកិច្ចកើនឡើង

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានកំណើនជាមធ្យម ៧% ក្នុងមួយឆ្នាំក្នុងអំឡុងឆ្នាំ ២០១០-២០១៩ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។[xlii] មានកត្តាជំរុញមួយចំនួន ដូចជាការនាំចេញសម្លៀកបំពាក់ និងទេសចរណ៍ កម្ពុជាមានចំណាត់ថ្នាក់ឈរនៅលើប្រទេសមីយ៉ាន់ម៉ា ទីម័រខាងកើត ឡាវ សិង្ហបុរី និងឥណ្ឌូណេស៊ី លើអត្រាកំណើនសេដ្ឋកិច្ច។[xliii] ដោយសារកំណើនសេដ្ឋកិច្ចនេះ កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្ដូរយ៉ាងសំខាន់ ដោយឈានដល់ឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ហើយកម្ពុជាបានបង្ហាញពី បំណងនៃការទទួលបានឋានៈប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០[xliv] ជាមួយនឹងប្រាក់ចំណូលជាតិសរុប (GNI) សម្រាប់មនុស្សម្នាក់នៅចន្លោះ ៤,៤៣២ ដុល្លារក្នុងឆ្នាំ ២០២២។[xlv]

ចំណែកផលប៉ះពាល់ពីជំងឺកូវីដ១៩ មកលើការអភិវឌ្ឍកម្ពុជាមានតិចតួច ដោយកំណើនផលិតផលក្នុងស្រុកសរុប-៣.១% ក្នុងឆ្នាំ២០២០ ប៉ុន្តែនៅឆ្នាំ២០២១ បានស្ទុះងើបឡើងវិញដល់ +៣% ។[xlvi] ការងើបឡើងវិញយ៉ាងឆាប់រហ័សនេះ បានមកពីឧស្សាហកម្មនាំចេញសម្លៀកបំពាក់ និងស្បែកជើង។ ឧស្សាហកម្មទាំងពីរនេះមានចំនួន ៦៣.៧% នៃការនាំចេញទំនិញសរុប (មិនរាប់បញ្ចូលមាស) ក្នុងឆ្នាំ ២០២១។[xlvii] ធនាគារពិភពលោក (WB) ព្យាករណ៍ថាកំណើនផលិតផលក្នុងស្រុក GDP នឹងកើនឡើងដល់ ៥.២%។[xlviii]

### ៥.៣.២. ផលប៉ះពាល់ពីសេដ្ឋកិច្ចពិភពលោក និងបញ្ហាសិទ្ធិមនុស្ស

បើទោះបីជាមានការព្យាករណ៍ជាវិជ្ជមានទាំងនេះទាក់ទងនឹងកំណើនសេដ្ឋកិច្ចជាតិក៏ដោយ ក៏ប្រជាពលរដ្ឋងាយរងគ្រោះត្រូវបានទុកចោលឱ្យកាន់តែលំបាកដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ និងអតិផរណាពិភពលោក។ ជាឧទាហរណ៍ កម្មករកាត់ដេរជាច្រើនបានទទួលប្រាក់ចំណូលប្រចាំខែទាបនៅឆ្នាំ ២០២២ ជាងមុនការរាតត្បាត Covid-១៩ ទោះបីជាប្រាក់ឈ្នួលអប្បបរមាបានកើនឡើងក្នុងរយៈពេលដំណាលគ្នាក៏ដោយ។ ដោយសារជំងឺរាតត្បាតនេះ ពួកគេបានបង្កើនប្រាក់កម្ចីក្រៅប្រព័ន្ធ ហើយក្នុងករណីខ្លះពួកគេខ្ចីផ្ទាល់ពីអ្នកគ្រប់គ្រងរោងចក្រ[xlix] ដែលអាចបង្កហានិភ័យដល់ "សិទ្ធិក្នុងការជ្រើសរើសការងារ មានលក្ខខណ្ឌសមរម្យ អំណោយផល និងប្រាក់ខែស្មើៗគ្នា។[l]

សម្រាប់ស្ថានភាពផ្សេងទៀតនៃប្រជាពលរដ្ឋកម្ពុជា បំណុលក្នុងគ្រួសារ (ជារឿយៗត្រូវបានប្រើដោះស្រាយវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរក្នុងគ្រួសារ) គឺជាហេតុផលចម្បងក្នុងការធ្វើចំណាកស្រុក សម្រាប់គ្រួសារដែលមានចំណូលទាប

ប៉ុន្តែវាបានប្រឈមភាពងាយរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ច ហើយបានបង្កបញ្ហាអវិជ្ជមានខាងសេដ្ឋកិច្ច សង្គម និង ផ្លូវចិត្ត នៅពេលពួកគេត្រឡប់មកសហគមន៍របស់ពួកគេវិញ»។[li]

## ៥.៤ បរិបទសង្គម

ដូចដែលបានលើកយកមកពិភាក្សានៅក្នុងផ្នែកទី ៣ និងបានពិពណ៌នានៅក្នុងរូបភាពនៅទំព័រទី ៣ បញ្ហាដែល API មានបំណងលើកឡើងមកពិភាក្សាត្រូវបានកំណត់ដោយដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយមួយ។ សម្រាប់វិស័យសង្គម អ្នកពាក់ព័ន្ធបានកំណត់បញ្ហាដូចខាងក្រោម។[lii]

### ៥.៤.១. ការពង្រីកកិច្ចគាំពារសង្គមដល់ទាំងអស់គ្នា

កិច្ចគាំពារសង្គមត្រូវបានផ្តល់តាមរយៈយន្តការពីរ៖ ១) ការធានារ៉ាប់រងសង្គម (ឧ. បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស) ដែលផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករក្នុងប្រព័ន្ធ ក្នុងករណីមានវ័យចំណាស់ មានពិការភាព មរណភាព របួសការងារ ជំងឺ និងមាតុភាព និង ២) របបសន្តិសុខសង្គម ដែលរួមមានប័ណ្ណសមធម៌ IDPoor/Equity (ចេញដោយមន្ទីរផែនការខេត្ត) និងមូលនិធិសមធម៌សុខាភិបាល (ចេញដោយ ក្រសួងសុខាភិបាល)។

ទោះជាយ៉ាងណាក៏ដោយ ប.ស.ស គ្របដណ្តប់តែកម្មករក្នុងប្រព័ន្ធប៉ុណ្ណោះ (ជាមួយនឹងគំនិតផ្តួចផ្តើមមួយចំនួនដើម្បីពង្រីកដល់កម្មករក្រៅប្រព័ន្ធក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ)។ មានតម្រូវការក្នុងការពង្រីកការគ្របដណ្តប់របស់ខ្លួនដល់កម្មករទាំងអស់ រួមទាំងអ្នកលក់តាមចិញ្ចើមផ្លូវផងដែរ។[liii]

ការចំណាយ ៦០% លើសុខភាពត្រូវបានបង់ដោយការចំណាយថវិកាខ្លួនឯងដែលធ្វើឱ្យសេវាសុខភាពពិបាកក្នុងការទទួលយកបានសម្រាប់គ្រួសារក្រីក្រ។[liv] បច្ចុប្បន្ននេះមានវិសមភាពគួរឱ្យកត់សម្គាល់នៅក្នុងបញ្ហាសុខភាពជាពិសេសសម្រាប់ក្រុមជនដែលខ្វះខាត។ មូលនិធិសមធម៌សុខាភិបាលរបស់ក្រសួងសុខាភិបាល ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ២០០០ បានកើនឡើងនូវលទ្ធភាពផ្តល់សេវាថែទាំសុខភាព។ ប៉ុន្តែនៅតែមានតម្រូវការច្រើនសន្ធឹកសន្ធាប់ទៀត ដើម្បីធ្វើឱ្យមនុស្សដែលមានការលំបាកកាន់តែច្រើនអាចប្រើប្រាស់បាន។ យោងតាមយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់បុគ្គលដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់ការងារសម្រាប់ឆ្នាំ ២០១៤-២០១៨ មានបញ្ហាប្រឈមជាច្រើនទាក់ទងនឹងការអនុលោមតាមនិយោជក និងនិយោជិតដែលមិនមានឯកសារត្រឹមត្រូវ។ និយោជិតបានសម្តែងការព្រួយបារម្ភអំពីគុណភាពនៃសេវាសុខភាពដែលផ្តល់តាមរយៈយន្តការនេះ។[lv]

## ៥.៥ បរិបទច្បាប់

### ៥.៥.១. កំណែទម្រង់ប្រព័ន្ធតុលាការកំពុងដំណើរការ ប៉ុន្តែមានភាពយឺតយ៉ាវ

ប្រព័ន្ធច្បាប់នៅកម្ពុជានៅតែកំពុងអភិវឌ្ឍ ហើយមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។ ជាឧទាហរណ៍ សាលក្រមដែលចេញដោយតុលាការមិនត្រូវបានផ្សព្វផ្សាយផ្លូវការជាសាធារណៈទេ ហើយវាមិនបង្កភាពងាយស្រួលសម្រាប់សាធារណជនក្នុងការចូលទៅមើល ឬយកមកប្រើប្រាស់។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៤១ ក្នុងចំណោម ១៤២ នៅក្នុងសន្ទស្សន៍នីតិរដ្ឋឆ្នាំ ២០២៣[lvi] ដែលបង្ហាញថា តុលាការមានភាពលំអៀង និងមិនឯករាជ្យ។

### ៥.៥.២. ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

គម្រោងសំខាន់របស់ API តាំងពីឆ្នាំ ២០០៧ គឺការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន (A2I)។ គេរំពឹងថាច្បាប់នេះត្រូវបានប្រកាសឱ្យប្រើក្នុងកំឡុងសម័យកាលរាជរដ្ឋាភិបាលបច្ចុប្បន្ន (២០២៣-២០២៨) ដែលអាចជួយសម្រួលដល់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់ប្រព័ន្ធតុលាការ តាមរយៈការអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចូលរួមដឹងឮការកាត់ក្តីរបស់តុលាការ។

## ៥.៦ បរិបទបច្ចេកវិទ្យា

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះឌីជីថលនីយកម្ម គឺជាកត្តាសំខាន់ដែលជំរុញការអភិវឌ្ឍបច្ចេកវិទ្យានៅកម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើតសេដ្ឋកិច្ចឌីជីថលនិងក្របខណ្ឌសង្គម[lvii] និងការបង្កើនលទ្ធភាពនៃការប្រើប្រាស់ទូរស័ព្ទទំនើប និងការប្រើប្រាស់អ៊ីនធឺណែត បានរួមចំណែកបន្ថែមទៀតដល់ការពង្រីកបច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា។

### ៥.៦.១. បច្ចេកវិទ្យាឌីជីថលជាវិធីសាស្ត្រផ្តល់សេវាថ្មី

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NCDDS សង្កត់ធ្ងន់លើការពាក់ព័ន្ធនៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការផ្តល់សេវា ការត្រួតពិនិត្យនិងការផ្តល់មតិកែលម្អលើគុណភាពសេ-វាកម្មប្រកបដោយប្រសិទ្ធភាព។[lviii] បច្ចេកវិទ្យាឌីជីថលលើកកម្ពស់ "ការធ្វើសមាហរណកម្មនៃបច្ចេកវិទ្យាឌីជីថលក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ" នឹងជំរុញឱ្យមានការប្រើប្រាស់កាន់តែច្រើនឡើងទៀតនូវឧបករណ៍ឌីជីថលដែលខ្លួនបានបង្កើតក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ ដែលអាចក្លាយជាជម្រើសរបស់ប្រជាពលរដ្ឋសម្រាប់ប័ណ្ណដាក់ពិន្ទុ។

### ៥.៦.២. ការគ្រប់គ្រង និងសុវត្ថិភាពតាមអ៊ីនធឺណិត

នៅខែកុម្ភៈ ឆ្នាំ ២០២១ រាជរដ្ឋាភិបាលបានអនុម័ត "ច្រកផ្លូវអ៊ីនធឺណិតជាតិ" ដើម្បី "ធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ធានាសណ្តាប់ធ្នាប់សង្គម និងការគ្រប់គ្រង វប្បធម៌ និងអរិយធម៌ឱ្យបានប្រសើរជាងមុន"។[lix] ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌមិនច្បាស់លាស់ទាំងនេះផ្តល់ឱ្យរាជរដ្ឋាភិបាលនូវជម្រើសដើម្បីរារាំងអ្នកប្រើប្រាស់ ក្នុងការចូលប្រើព័ត៌មានដែលចាត់ទុកថាមានសារៈសំខាន់ចំពោះដំណើរការអនុត្ត។

សម្រាប់ការពង្រឹងសន្តិសុខតាមអនឡាញ សេចក្តីព្រាងច្បាប់សុវត្ថិភាពអនឡាញ Cyber Security អាចផ្តល់ឱ្យរាជរដ្ឋាភិបាលពង្រីកអំណាចរបស់ខ្លួនដើម្បីរឹបអូសយកប្រព័ន្ធកុំព្យូទ័រពីក្រុមហ៊ុននានា។[lx] ដូច្នេះហើយច្បាប់វាក៏ជាឧបករណ៍ដ៏មានឥទ្ធិពលមួយប្រឆាំងនឹងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ និងសិទ្ធិឯកជនភាពរបស់ប្រជាពលរដ្ឋផងដែរ។[lxi] ការត្រួតពិនិត្យជាបន្តបន្ទាប់នៃដំណើរការព្រាងច្បាប់គឺចាំបាច់ដើម្បីធានាថាច្បាប់ថ្មីនេះនឹងមិនគាបសង្កត់សិទ្ធិបុគ្គលឡើយ។

## ៥.៧ បរិបទបរិស្ថាន

### ៥.៧.១. ការគ្រប់គ្រងធនធានជាតិ

គេនៅសង្កេតឃើញមានបញ្ហាប្រឈមក្នុងអភិបាលកិច្ចនៃការគ្រប់គ្រងធនធានជាតិ ជាពិសេសទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើ បម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានទឹក និងសមុទ្រ។ ជាក់ស្តែងពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០២២ កម្ពុជាបានបាត់បង់គម្របព្រៃឈើចំនួន ៩២៣,០០០ ហិកតា នៅក្នុងតំបន់ការពារ (១៧% នៃផ្ទៃដីគម្របព្រៃឈើរបស់ប្រទេសក្នុងឆ្នាំ ២០០០) ដែលក្នុងនោះមាន២១៥,០០០ ហិកតា (២៣%) ត្រូវបានបាត់បង់ក្នុងអំឡុងឆ្នាំ ២០២០-២០២២។[lxii] មូលហេតុចម្បងនៃការបាត់បង់ព្រៃឈើគឺផលិតកម្មកៅស៊ូ (ក្នុងដីសម្បទាន សេដ្ឋកិច្ច)។ ផ្ទៃដីប្រហែល ៦៩៩,០០០ ហិកតា ឬ ៣.៩% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជាត្រូវបានបម្រុងទុកសម្រាប់ចម្ការកៅស៊ូ ដែលជារឿយៗស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ច (ELC)[lxiii] ការកាប់បំផ្លាញព្រៃឈើបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទ ជាពិសេសក្រុមជនជាតិដើមភាគតិច និងបណ្តាលឱ្យដីមានសំណឹក ការជន់លិច ការបាត់បង់ជីវៈចម្រុះ និងការបាត់បង់លទ្ធភាពស្តុកកាបូន និងធ្វើឱ្យបម្រែបម្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរឡើង។

### ៥.៧.២. បម្រែបម្រួលអាកាសធាតុ

យោងតាមសន្ទស្សន៍ហានិភ័យអាកាសធាតុសកលក្នុងឆ្នាំ ២០២០ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ជាប្រទេសដែលងាយរងគ្រោះបំផុតទី១២ ចំពោះបម្រែបម្រួលអាកាសធាតុជាសកល។[lxiv] ប្រទេសកម្ពុជាប្រឈមមុខខ្ពស់ និងងាយរងគ្រោះផងដែរ សម្រាប់បម្រែបម្រួលអាកាសធាតុ ដោយសារសេដ្ឋកិច្ចរបស់ខ្លួនពឹងផ្អែកខ្លាំងលើវិស័យដែលងាយនឹងប៉ះពាល់ដោយសារបម្រែបម្រួលអាកាសធាតុ ដូចជាវិស័យកសិកម្ម ធនធានទឹក ព្រៃឈើ នេសាទ និងទេសចរណ៍។[lxv] ធនាគារពិភពលោក WB និងធនាគារអភិវឌ្ឍន៍អាស៊ី ADB (២០២១) បានធ្វើការសន្និដ្ឋានថា "ផលប៉ះពាល់ [នៃបម្រែបម្រួលអាកាសធាតុ] អាចធ្វើឱ្យមានបញ្ហាកាន់តែខ្លាំងលើវិបត្តិដែលមានស្រាប់នៃវិសមភាពទ្រព្យសម្បត្តិ និងវិសមភាពប្រាក់ចំណូល ហើយវានឹងរារាំងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រក្នុងប្រទេស។[lxvi]"

ចំនួនប្រជាជនដែលនឹងប្រឈមមុខខ្លាំងក្លានឹងទឹកជំនន់តាមដងទន្លេអាចកើនឡើងដល់ប្រហែល ៤ លាននាក់នាទសវត្សរ៍ឆ្នាំ ២៥៤០។[lxvii] គេរំពឹងថាទឹកជំនន់ធ្ងន់ធ្ងរ និងគ្រោះរាំងស្ងួត នឹងបណ្តាលឱ្យបាត់បង់ផលិតផល ១០% ក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជានៅឆ្នាំ ២០៥០។[lxviii] ដើម្បីដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ រាជរដ្ឋាភិបាលបានអនុម័ត ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុ (២០១៤-២០២៣) ហើយបាននឹងកំពុងរៀបចំ ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុលើកទីពីរ (២០២៤-២០៣៣) ។

# ៦ ទិសដៅយុទ្ធសាស្ត្រ ២០២៤ - ២៨

## ៦.១ ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ API ២០២៤-២៨

តួលេខនៅលើទំព័រខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងលទ្ធផល គោលបំណង និងគោលដៅរបស់ API សម្រាប់ឆ្នាំ ២០២៨។ ពាក្យពេញលេញនៃធាតុនីមួយៗនៅក្នុងតួលេខនេះត្រូវបានបង្ហាញនៅក្នុងផ្នែក ៦.២ និង ៦.៣ ។ តួលេខនេះបង្ហាញជាពណ៌បៃតង អត្ថន័យនៃពាក្យ "មានភាពចុះសម្រុងគ្នា" នៅក្នុងគោលដៅ និងការគាំទ្រ API អាចផ្តល់ការអភិវឌ្ឍលក្ខណៈនិរន្តរភាពបន្ថែមទៀត ចំពោះការសម្រេចបាននូវគោលបំណង និងគោលដៅ។

**កម្រាស់នៃព្រួញឆ្លុះបញ្ចាំង** ពីការគ្រប់គ្រងរបស់ API លើការសម្រេចបាននូវឥទ្ធិពលដែលបានគ្រោងទុក។



ផែនការយុទ្ធសាស្ត្រនេះ គឺស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិឆ្នាំ២០២៤-២០២៨ដែលមានលទ្ធផលដូចដែលបានគ្រោងទុកៈ "នៅត្រឹមឆ្នាំ ២០២៨ ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលប្រឈមនឹងហានិភ័យនៃការមិនអើពើ នឹងរស់នៅក្នុងសង្គមមួយដែលមានសមភាពយេនឌ័រ និងប្រកបដោយបរិយាបន្ន ជាមួយនឹងលំហពលរដ្ឋសកម្ម និងពេញចិត្តនឹងស្ថាប័នដែល និងមានគណនេយ្យភាពជាងមុន។[១៩]

ជាពិសេស API គាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG)១៦ "សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ" ដែលក្នុងនោះ API រួមចំណែកដល់៖

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG ១៦.៦ ដើម្បី "អភិវឌ្ឍស្ថាប័នប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពគ្រប់កម្រិត»។
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG ១៦.៦.២ "សមាមាត្រនៃចំនួនប្រជាជនដែលពេញចិត្ត ជាមួយ នឹងបទពិសោធន៍ចុងក្រោយលើសេវាកម្មសាធារណៈ» និង
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG ១៦.១០ ដើម្បីធានាការទទួលបានព័ត៌មានជាសាធារណៈ និងសេរីភាពជាមូលដ្ឋាន"។

យុទ្ធសាស្ត្រ API ក៏មានសក្តានុពលក្នុងការរួមចំណែកដល់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG ១ លើភាពក្រីក្រ SDG ៤ លើការអប់រំ SDG ៥ លើសមភាពយេនឌ័រ SDG ៨ លើការងារសមរម្យ និងកំណើនសេដ្ឋកិច្ច SDG ១០ លើការកាត់បន្ថយវិសមភាព និង SDG ១៣ សកម្មភាពអាកាសធាតុ។

## ៦.២ បំណងប្រាថ្នារបស់ API

**ចក្ខុវិស័យរបស់ API** ប្រទេសកម្ពុជាមានវប្បធម៌ជាតិនៃភាពសុខដុមរមនា ជាមួយស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្សដើម្បីអនាគតដរុងរឿងសម្រាប់ទាំងអស់គ្នា។

**បេសកកម្ម** ដើម្បីបម្រើតម្រូវការអភិវឌ្ឍន៍សង្គម និងលទ្ធិប្រជាធិបតេយ្យរយៈពេលវែងរបស់ប្រទេសកម្ពុជា តាមរយៈការពង្រឹងសិទ្ធិអំណាចពលរដ្ឋក្នុងការប្រាស្រ័យទាក់ទង ជាមួយរដ្ឋាភិបាលដើម្បីការពារសិទ្ធិរបស់ពួកគេ។

**គោលដៅរបស់ API** សម្រាប់ផែនការយុទ្ធសាស្ត្រនេះ៖ នៅត្រឹមឆ្នាំ ២០២៨ ប្រទេសកម្ពុជានឹងកាន់តែមានភាពសុខដុមរមនា មានបរិយាបន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ និងការគោរពគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

### បញ្ហាអន្តរវិស័យ

ស្ត្រី កុមារី យុវជន ប្រជាពលរដ្ឋងាយរងគ្រោះ ការអភិវឌ្ឍឌីជីថល ការគ្រប់គ្រងធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ។

### វិធីសាស្ត្រនៃការអនុវត្តៈ

វិធីសាស្ត្រក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានកំណត់លក្ខណៈដោយ (១) ការទទួលយកភាពចម្រុះ និងបរិយាបន្នក្នុងសង្គមជាមួយនឹងគោលការណ៍ "គ្មាននរណាម្នាក់ត្រូវបានទុកចោល" (២) ការប្រកាន់ខ្ជាប់

យ៉ាងតឹងរ៉ឹងចំពោះគោលការណ៍មិនបង្កគ្រោះថ្នាក់ Do No Harm (រួមទាំងការវិភាគផលប៉ះពាល់អវិជ្ជមាន នៃសកម្មភាពរបស់ API ដែលអាចកើតមានឡើង មុនពេលនៃការចាប់ផ្តើមសកម្មភាព) (៣) ការចូលរួមជាបន្តបន្ទាប់របស់អ្នកទទួលផលក្នុងការសម្រេចចិត្ត និង (៤) កិច្ចសហការល្អបំផុតជាមួយស្ថាប័នផ្សេងទៀតដែលមានគោលដៅដូចគ្នា។

## ៦.៣ គោលបំណង លទ្ធផល គោលដៅ និងសកម្មភាព

### គោលបំណង១ កែលម្អអភិបាលកិច្ចប្រជាធិបតេយ្យ និងគណនេយ្យភាព

គោលបំណងនេះសំដៅលើតម្រូវការកែលម្អអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រោមជាតិ អ្នកត្រួតពិនិត្យ ការយល់ដឹង និងការចូលរួមមានកម្រិតរបស់ប្រជាពលរដ្ឋអំពីអភិបាលកិច្ចល្អ តម្រូវការគណនេយ្យភាព និងការកើនឡើងនៃវិមជ្ឈការ។

**លទ្ធផល ១.១** រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពអនុវត្តមុខងារ (វិមជ្ឈការ) របស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ បរិយាបន្ន សមភាព និងយុត្តិធម៌។

**គោលដៅ ១.១** ភាគរយនៃមន្ត្រីនៅក្នុងតំបន់គោលដៅបង្ហាញថាពួកគេអាចអនុវត្តមុខងាររបស់ពួកគេបានប្រសើរជាងមុន។

### សកម្មភាពយុទ្ធសាស្ត្រ

ក្នុងភាពជាដៃគូជាមួយ NCDDS វិទ្យាស្ថានជាតិនៃរដ្ឋបាលមូលដ្ឋាន (NASLA) របស់ NCDDS សម្ព័ន្ធជាតិនៃក្រុមប្រឹក្សាមូលដ្ឋាន និងសាកលវិទ្យាល័យ។

វិធានការអភិវឌ្ឍសមត្ថភាពសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើត និងអនុវត្ត។ ក្នុង ចំណោមនោះពាក់ព័ន្ធនឹងអនុក្រឹត្យរបស់រដ្ឋាភិបាល លេខ ១៨២ ១៨៣ និង ១៨៤ ដែលបញ្ជាក់ពីមុខងារវិមជ្ឈការដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (រួមទាំងការិយាល័យច្រកចេញចូលតែមួយ) និងសិទ្ធិក្នុងការទទួលបានព័ត៌មាន។

**លទ្ធផល ១.២** អង្គការសហគមន៍មូលដ្ឋាន CBOs កំពុងត្រួតពិនិត្យមុខងារ និងសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលជួបការលំបាកភាគច្រើន។

**គោលដៅ ១.២.១** យ៉ាងហោចណាស់ អង្គការសហគមន៍មូលដ្ឋានចំនួន ៥០ CBOs កំពុងត្រួតពិនិត្យ និងចូលរួមជាមួយមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់ពីទទួលបានការអភិវឌ្ឍសមត្ថភាពពី API។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងពង្រឹងសិទ្ធិអំណាចអង្គការសហគមន៍មូលដ្ឋាន CBOs (អ្នកសារព័ត៌មាន ក្រុមជនងាយរងគ្រោះ ក្រុមយុវជន ការគ្រប់គ្រងធនធានធម្មជាតិNRM CBOs) តាមរយៈការបណ្តុះបណ្តាល រៀបចំវេទិកា ឌីជីថល និងការបង្វឹកហាត់។

**គោលដៅ ១.២.២** ការសន្ទនាប្រកបដោយលក្ខណៈស្ថាបនា និងទៀងទាត់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និង/អង្គការសហគមន៍មូលដ្ឋាន CBOs និងសមាជិកដែលបានធ្វើឡើងនៅក្នុងចំនួន ៣០ ស្រុក។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងជួយរៀបចំការសន្ទនាប្រកបដោយការស្ថាបនាអំពីគុណភាពនៃសេវាសាធារណៈ នៅក្នុងស្រុកចំនួន ៣០ ក្នុងខេត្តគោលដៅ។ សកម្មភាពនេះនឹងរួមបញ្ចូលការប្រើប្រាស់ឧបករណ៍ដែលមានស្រាប់ដែលបានធ្វើបច្ចុប្បន្នភាព និងការអភិវឌ្ឍឧបករណ៍ថ្មីផងដែរ ដោយធ្វើការពិចារណាលើផែនការរបស់ ក្រសួងមហាផ្ទៃសម្រាប់រាជរដ្ឋាភិបាលអេឡិចត្រូនិក។ កិច្ចសន្ទនាទាំងនេះក៏បម្រើគោលបំណងនៃការកសាងទំនុកចិត្តរវាង រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ និង អង្គការសហគមន៍មូលដ្ឋាន CBOs។ ពួកគេនឹងពិភាក្សាអំពីកង្វល់របស់ប្រជាពលរដ្ឋ និងកំណត់នូវដំណោះស្រាយដែលនឹងអាចកើតមាន។

**លទ្ធផល ១.៣** ប្រជាពលរដ្ឋ (រួមទាំងប្រជាពលរដ្ឋដែលជួបការលំបាកភាគច្រើន) ចូលរួមកាន់តែសកម្មក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ពួកគេ។

**គោលដៅ ១.៣.១** ចំនួនភាគរយនៃប្រជាពលរដ្ឋ (ស្ត្រី ៥០%) បានបង្កើនការយល់ដឹងអំពីមុខងារ និងសេវាកម្មវិមជ្ឈការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពយុទ្ធសាស្ត្រ

ដោយមានភាពជាដៃគូជាមួយស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ (រាប់បញ្ចូលទាំង NCDDS និង SNAs) API នឹងបង្កើតកម្មវិធីពង្រឹងសមត្ថភាពសម្រាប់ប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម វេទិកាសិក្សាតាមអ៊ីនធឺណិតអនឡាញ វិទ្យាល័យ និងសាកលវិទ្យាល័យ។ ប្រជាពលរដ្ឋនឹងទទួលបានការយល់ដឹងកាន់តែប្រសើរឡើងអំពីមុខងារ និងសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងគណនេយ្យភាព តម្លាភាព និងមុខងាររបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ តាមរយៈវេទិកាឌីជីថល។

ការអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋនេះនឹងទទួលបានការគាំទ្រដោយការស្រាវជ្រាវវិទ្យាសាស្ត្ររបស់ API អមដោយកិច្ចពិភាក្សាគោលនយោបាយនឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ កំណត់ថវិកា និងដំណើរការលទ្ធកម្មសាធារណៈ។

**គោលដៅ ១.៣.២** ចំនួនភាគរយនៃប្រជាពលរដ្ឋ (ស្ត្រី ៥០%) ដែលការយល់ដឹងរបស់ពួកគេត្រូវបានពង្រឹងដោយសកម្មភាពដែលដឹកនាំដោយ API កំពុងត្រួតពិនិត្យសេវាកម្ម (ផ្តល់ជូនពួកគេ និងក្រុមគ្រួសារ សាច់ញាតិ និងមិត្តភក្តិ) និងមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ ផ្សេងទៀត (ភាគរយនឹងត្រូវកំណត់បន្ទាប់ពីការបញ្ចប់ការស្ទង់មតិមូលដ្ឋាន)។

### សកម្មភាពយុទ្ធសាស្ត្រ

សមត្ថភាពត្រួតពិនិត្យតាមដាន (ចំណេះដឹង និងជំនាញ) របស់ប្រជាពលរដ្ឋដែលបានចូលរួមក្នុងសកម្មភាពដឹកនាំ API (ក្រោមគោលដៅ ១.២.១) នឹងត្រូវបានបង្កើតឡើងតាមរយៈការបណ្តុះបណ្តាលអំពីវិធីដែលពួកគេអាចត្រួតពិនិត្យសេវាកម្ម និងចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសន្ទនាក្នុងន័យស្ថាបនាអំពីគុណភាពនៃសេវាកម្ម។ API នឹងប្រើប្រាស់វិធីសាស្ត្រគណនេយ្យភាពសង្គមស្តង់ដា (I-SAF និងមិនមែនគណនេយ្យភាពសង្គមស្តង់ដា ISAF ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងការត្រួតពិនិត្យតាមដាន។

ថវិកា និងការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានត្រួតពិនិត្យ ដោយមានជំនួយពីកម្មវិធីវិភាគថវិកាប្រជាពលរដ្ឋ ហើយសេវាច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានត្រួតពិនិត្យតាមរយៈកម្មវិធីសន្ទនាជាមួយបណ្តាញសង្គម Pidor Chatbot ដែលកម្មវិធីទាំងពីរនឹងត្រូវបានធ្វើបច្ចុប្បន្នភាពដោយ API និងដៃគូរបស់ខ្លួន។

**គោលដៅ ១.៣.៣** យុវជន ស្ត្រី និងប្រជាពលរដ្ឋជួបការលំបាក កំពុងចូលរួមក្នុងផែនការ និងការសម្រេចចិត្តរបស់ឃុំ/សង្កាត់គោលដៅរបស់ខ្លួន (ភាគរយនឹងត្រូវបានកំណត់បន្ទាប់ពីបញ្ចប់ការស្ទង់មតិមូលដ្ឋាន)។

### សកម្មភាពយុទ្ធសាស្ត្រ

តាមរយៈការប្រើប្រាស់វគ្គបណ្តុះបណ្តាល វេទិកា និងវេទិកាឌីជីថល API នឹងរៀបចំអប់រំយុវជន ស្ត្រី និងអ្នកងាយរងគ្រោះអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេនៅក្នុងសង្គមប្រជាធិបតេយ្យ រួមទាំងសិទ្ធិរបស់ពួកគេក្នុងការទាមទារការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

**គោលដៅ ១.៤** ភាគរយនៃប្រជាពលរដ្ឋ (ស្ត្រី ៥០%) នៅក្នុងតំបន់គោលដៅដែលធ្វើការសង្កេតមើលភាពប្រសើរឡើងនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចដែលបានបង្ហាញចេញពីប័ណ្ណពិន្ទុរបស់ប្រជាពលរដ្ឋ និងការសន្ទនាទល់មុខគ្នា។

### សកម្មភាពយុទ្ធសាស្ត្រ

API មានបំណងគាំទ្រសកម្មភាពរដ្ឋរបស់កម្មវិធីគណនេយ្យភាពសង្គម I-SAF ដែលផ្តោតលើបរិស្ថាន ទឹកស្អាត អនាម័យ បម្រែបម្រួលអាកាសធាតុ និងវិស័យកសិកម្ម ដោយគាំទ្រឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ API នឹងបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យស្នើសុំសេវាសង្គម និងរដ្ឋបាលតាមរយៈការផ្តល់ព័ត៌មានដល់ និងជំនួយផ្នែករដ្ឋបាល ភ័ស្តុភារ និងបច្ចេកទេស។ API ក៏នឹងប្រមូល និងវិភាគព័ត៌មានអំពីបទពិសោធន៍របស់ប្រជាពលរដ្ឋ (ផ្អែកលើតារាងពិន្ទុឌីជីថល) និងរៀបចំសេចក្តីសង្ខេបគោលនយោបាយសម្រាប់ការតស៊ូមតិ។

**គោលបំណងទី២** **ការតាក់តែង ការអនុវត្ត និងការត្រួតពិនិត្យ ច្បាប់ និងគោលនយោបាយសាធារណៈមានបរិយាបន្ន និងលទ្ធិប្រជាធិបតេយ្យ ។**

គោលបំណងខាងលើនេះនឹងលើកឡើងនូវបញ្ហាដូចខាងក្រោម៖ បង្កើនការគាំទ្រសម្រាប់ការបង្កើតគោលនយោបាយ និងច្បាប់ថ្មីដោយរួមបញ្ចូលតាមរយៈការពិគ្រោះយោបល់ជាសាធារណៈបន្ថែមទៀតទាក់ទងនឹងការគ្រប់គ្រងធនធានជាតិ (NRM) បម្រែបម្រួលអាកាសធាតុ បញ្ហាសង្គម និងដើម្បីឆ្លើយតបនឹង តម្រូវការចាំបាច់សម្រាប់គោលនយោបាយ ផ្អែកលើការស្រាវជ្រាវ និងអនុសាសន៍ផ្លូវច្បាប់។

**លទ្ធផល ២.១** **សំឡេងនៃអ្នកងាយរងគ្រោះភាគច្រើនមកពីសហគមន៍ និងយុវជនពីវិទ្យាល័យ និងសាកលវិទ្យាល័យ ត្រូវបានទទួលដឹងឮ និងលើកឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។**

**គោលដៅ ២.១** ប្រជាពលរដ្ឋ (ស្ត្រី ៥០%) ទទួលបានចំណេះដឹងអំពីការគ្រប់គ្រងធនធានធម្មជាតិនិងបម្រែបម្រួលបរិយាកាស។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងធ្វើយុទ្ធនាការបញ្ជ្រាបពីការគ្រប់គ្រងធនធានធម្មជាតិ (រួមទាំងសិទ្ធអាស្រ័យផល) និងបម្រែបម្រួលអាកាសធាតុ តាមរយៈកម្មវិធីសិក្សាដោយផ្ទាល់ នៅតាមបណ្តាសាកលវិទ្យាល័យ វេទិកាសិក្សាអនឡាញ និងយុទ្ធនាផ្សព្វផ្សាយតាមបណ្តាញសង្គម។ យុទ្ធនាការទាំងនេះនឹង ធ្វើឡើងដោយសហការគ្នា ជាពិសេសនៅតាមសហគមន៍ដែលរងផលប៉ះពាល់ខ្លាំងដោយបញ្ហា ការគ្រប់គ្រងធនធានធម្មជាតិ (NRM) និងបម្រែបម្រួលអាកាសធាតុ។

**គោលដៅ ២.១.២** នៅក្នុងសហគមន៍ចំនួន ៥០ ដែលរងផលប៉ះពាល់ដោយបញ្ហា ការគ្រប់គ្រងធនធានធម្មជាតិ (NRM) និងបម្រែបម្រួលអាកាសធាតុ ប្រជាពលរដ្ឋដែលងាយរងគ្រោះកំពុងការពារធនធានធម្មជាតិ និងលើកឡើងពីកង្វល់របស់ពួកគេចំពោះឥទ្ធិពលគោលនយោបាយ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងកំណត់អត្តសញ្ញាណក្រុមតំណាងសំខាន់ៗនៃប្រជាពលរដ្ឋងាយរងគ្រោះ រៀបចំ TNA និងបង្កើតកម្មវិធីសិក្សា ផ្តល់វគ្គបណ្តុះបណ្តាល ការណែនាំ និងជំនួយបច្ចេកទេស។ ក្រុមទាំងនេះនឹងត្រូវបានគាំទ្រតាមរយៈការចុះសួរសុខទុក្ខ និងកិច្ចពិភាក្សាគោលនយោបាយ ដើម្បីលើកឡើងពីកង្វល់របស់ពួកគេចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងរាជរដ្ឋាភិបាល។

**គោលដៅ ២.១.៣** សហគ្រាសធុនមធ្យម និងធំ គោរពតាមការត្រួតពិនិត្យសិទ្ធិមនុស្ស និងបរិស្ថាន និងគោរពបរិស្ថានធម្មជាតិកាន់តែខ្លាំងឡើង។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងគាំទ្រដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី យុវជន និងអ្នកងាយរងគ្រោះ ក្នុងការលើកឡើងពីការព្រួយបារម្ភអំពីសិទ្ធិមនុស្ស និងការអនុវត្តគោរពតាមគោលការណ៍បរិស្ថានរបស់សហគ្រាស។ API ក៏នឹងសហការយ៉ាងជិតស្និទ្ធជាមួយគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្មផងដែរ។

**លទ្ធផល ២.២** មានការស្រាវជ្រាវ និងភស្តុតាងបន្ថែមទៀតដែលគេអាចរកបានសម្រាប់ការសន្ទនាគោលនយោបាយ ការពង្រឹង និងការត្រួតពិនិត្យ។

**គោលដៅ២.២** ការសិក្សាស្រាវជ្រាវ និងរបកគំហើញ ចំនួន ១០ ត្រូវបានធ្វើឡើង និងធ្វើការផ្សព្វផ្សាយ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងបញ្ហាកង្វល់របស់ពលរដ្ឋ ដើម្បីប្រើប្រាស់ការសន្និដ្ឋានរបកគំហើញជាភស្តុតាង សម្រាប់ការតស៊ូមតិជាមួយ រាជរដ្ឋាភិបាល ដើម្បីបង្កើតគោលនយោបាយ និងច្បាប់។ ការសិក្សាទាំងនោះអាចគ្របដណ្តប់លើការបំពេញសិទ្ធិទទួលបានព័ត៌មាន សេរីភាពនៃការបញ្ចេញមតិ សិទ្ធិឌីជីថលវិមជ្ឈការ និងវិសហមជ្ឈការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចគាំពារសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច។ API នឹងរៀបចំកិច្ចសន្ទនាសង្ខេបពីគោលនយោបាយឱ្យបានទៀងទាត់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗរួមទាំងដៃគូអភិវឌ្ឍន៍ បណ្តាញអង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ វិស័យឯកជន និងស្ថាប័នរដ្ឋាភិបាលកណ្តាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋសភា ក៏ដូចជាវេទិកា និងយន្តការសន្ទនាអាស៊ាន និងសកល ដូចជាវេទិកាប្រជាជនអាស៊ានជាដើម។ ខណៈពេលដែលពិនិត្យ តាមដានសកម្មភាពលើរបាយការណ៍ត្រួតពិនិត្យជាសកលរបស់រាជរដ្ឋាភិបាល (ស្តីពីកំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជា) និងក្នុងអំឡុងពេលនៃការប្រារព្ធពិធីរួមគ្នានៃទិវាសិទ្ធិទទួលព័ត៌មាន ទិវាសិទ្ធិមនុស្ស សប្តាហ៍នៃកិច្ចគាំពារសង្គម និងវេទិកាអន្តរជាតិផ្សេងទៀត។

**លទ្ធផល ២.៣** អង្គការសហគមន៍មូលដ្ឋាន CBOs និងអង្គការសង្គមស៊ីវិល អាចជួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋជម្រុញឱ្យរដ្ឋាភិបាលមានគណនេយ្យភាពលើការអនុវត្តច្បាប់ និងគោលនយោបាយរបស់ខ្លួន។

**គោលដៅ ២.៣** អង្គការសហគមន៍មូលដ្ឋាន CBOs ចំនួន ៥០ និងសមាជិកនៃអង្គការសង្គមស៊ីវិល CSO ចំនួន ២០០ អង្គការសមាជិកនៃបណ្តាញអង្គការសមាជិក ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG), សម្ព័ន្ធភាពដៃគូអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD), ក្រុមការងារថវិកា (BWG), ក្រុមការងារសិទ្ធិឌីជីថល (DRWG), ក្រុមការងារកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា (SP4ALL), គណកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC), វេទិកានៃអង្គការមិនមែន រដ្ឋាភិបាលស្តីពីកម្ពុជា(NGO Forum), បណ្តាញអង្គការសង្គមស៊ីវិលខេត្តកំពុងជម្រុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) និងរដ្ឋាភិបាលថ្នាក់ជាតិមានគណនេយ្យភាពលើការអនុវត្តច្បាប់។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងបន្តអភិវឌ្ឍសមត្ថភាពតស៊ូមតិរបស់ អង្គការសហគមន៍មូលដ្ឋាន CBOs ស្ត្រី យុវជន អ្នកសារព័ត៌មានប្រជាពលរដ្ឋ និងបណ្ដាញអង្គការសង្គមស៊ីវិល CSO ថ្មី សមាជិកនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និង CamboJa តាមរយៈការបណ្ដុះបណ្ដាលគូនកាត់ វេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការណែនាំ។

តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសមាជិកបណ្ដាញ API នឹងធ្វើការតស៊ូមតិរួមគ្នាសម្រាប់ការអនុវត្តច្បាប់ និងការអនុវត្តគោលនយោបាយប្រកបដោយគណនេយ្យភាព និងមានប្រសិទ្ធភាពបន្ថែមទៀតទាក់ទងនឹង សិទ្ធិទទួលព័ត៌មាន, សិទ្ធិឌីជីថល កំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម ជាដើម។

**គោលបំណងទី៣** **សិទ្ធិមនុស្សត្រូវបានគោរព ការពារ និងបំពេញបន្ថែម**

គោលបំណងនេះដើម្បីលើកឡើងពីបញ្ហានៃការការពារ និងការបំពេញបន្ថែមសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដោយជម្រុញឱ្យមានការចូលរួមយ៉ាងសកម្មពីក្រុមជនដែលងាយរងគ្រោះ។

**លទ្ធផល ៣.១** ទទួលស្គាល់សិទ្ធិទទួលបានព័ត៌មាន

**គោលដៅ ៣.១.១** អនុម័តច្បាប់សិទ្ធិទទួលព័ត៌មាន ដោយមានធាតុចូលពីអង្គការសង្គមស៊ីវិល និងអនុវត្តនៅគ្រប់កម្រិតថ្នាក់ទាំងអស់

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងបន្តដឹកនាំក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) ដែលនឹងត្រូវបានតម្រឹមបន្ថែមទៀតជាមួយក្រុមការងារសិទ្ធិឌីជីថល សម្ព័ន្ធ និងបណ្ដាញផ្សេងទៀត ដើម្បីតស៊ូមតិសម្រាប់ការអនុម័តច្បាប់សិទ្ធិទទួលព័ត៌មាន។ នៅពេលដែលអនុម័តច្បាប់សិទ្ធិទទួលព័ត៌មាន API នឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់ក្រសួង រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកទទួលផល បណ្ដាញ និងអង្គការសហគមន៍មូលដ្ឋាន CBOs នៅលើក្របខ័ណ្ឌច្បាប់សិទ្ធិទទួលព័ត៌មាន ដើម្បីអនុវត្តច្បាប់សិទ្ធិទទួលព័ត៌មាន និងតាមដានពីរបៀបដែលវាត្រូវបានអនុវត្ត។

ទោះបីជាច្បាប់សិទ្ធិទទួលព័ត៌មានមិនត្រូវបានអនុម័តក្នុងអំឡុងពេលនេះក៏ដោយ API នឹងបន្តលើកទឹកចិត្តបុគ្គល និងរាជរដ្ឋាភិបាល ឱ្យអនុវត្តនិងពង្រឹងបទប្បញ្ញត្តិដែលមានស្រាប់សម្រាប់ការទទួលបានព័ត៌មានតាមវិស័យនីមួយៗ។

**គោលដៅ ៣.១.២** ស្រុកចំនួន ៣០ កំពុងបញ្ចេញព័ត៌មានយ៉ាងសកម្មដល់ប្រជាពលរដ្ឋរបស់ពួកគេ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងបន្តតស៊ូមតិដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ចេញព័ត៌មានដល់ប្រជាពលរដ្ឋ ដោយប្រើវេទិកាសាធារណៈរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ កិច្ចប្រជុំប្រចាំខែ វិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយសង្គម (ហ្វេសបុក តិកតុក អិនស្តាក្រាម)។ នៅពេលដែលច្បាប់សិទ្ធិទទួលព័ត៌មាន ចូលជាធរមាន វានឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិទាំងនេះ នៅក្នុងការពិគ្រោះយោបល់ជាមួយក្រសួងព័ត៌មាន។

ដើម្បីតាមដានការអនុវត្តច្បាប់ API នឹងរៀបចំសិក្ខាសាលាពហុភាគីជាមួយ SNAS, CBOs និងសមាជិក CSOs។ សកម្មភាពទាំងនេះនឹងបង្កើតរបាយការណ៍ជាប្រចាំអំពីរបៀបដែលប្រជាពលរដ្ឋ ជាពិសេសអ្នកសារព័ត៌មាន និងអាជីវកម្មអាចអនុវត្តសិទ្ធិទទួលបានព័ត៌មានដោយផ្អែកលើច្បាប់។

**គោលដៅ ៣.១.៣** ក្រសួងចំនួន ២០ ដែលជាសមាជិកនៃគណកម្មាធិការជាតិដើម្បីអភិវឌ្ឍបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) កំពុងបញ្ចេញព័ត៌មានយ៉ាងសកម្មដល់ប្រជាពលរដ្ឋ ស្របតាមបទប្បញ្ញត្តិដែលមានស្រាប់។

### សកម្មភាពយុទ្ធសាស្ត្រ

ជារៀងរាល់ឆ្នាំនៅថ្ងៃទិវាសិទ្ធិទទួលព័ត៌មាន (២៨ កញ្ញា) API នឹងរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយដែលមានការចូលរួមពីអ្នកទទួលផល និងក្រសួងចំនួន ២០ ដើម្បីពង្រឹងបទប្បញ្ញត្តិដែលមានស្រាប់ និងធានាថាការអនុវត្តប្រព្រឹត្តបានយ៉ាងល្អ ហើយព័ត៌មានតាមវិស័យត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ។

**លទ្ធផល ៣.២** ការអនុវត្ត និងការគោរព សេរីភាពនៃការបញ្ចេញមតិ

**គោលដៅ ៣.២.១** ភាគរយនៃប្រជាពលរដ្ឋ (ក្នុងនោះ ៥០% ជាស្ត្រី) មានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការបញ្ចេញមតិនិងកង្វល់របស់ពួកគេ ដែលជាលទ្ធផលបានមកពីការចូលរួមជាមួយសកម្មភាព API ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងរៀបចំការអប់រំអំពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយសង្គមរបស់ពលរដ្ឋ រួមទាំងសេរីភាពនៃការបញ្ចេញមតិ សិទ្ធិឌីជីថល និងសុវត្ថិភាពឌីជីថលដល់ក្រុមសកម្មជន និងអ្នកតស៊ូមតិ។ API ក៏នឹងរៀបចំសិក្ខាសាលាមួយដែលមានសកម្មជនគម្រូចែករំលែកការអនុវត្ត និងមេរៀនល្អៗក្នុងការបញ្ចេញមតិជាមួយសកម្មជនផ្សេងទៀតផងដែរ។

បន្ទាប់មក API នឹងបង្វឹកហាត់ដល់ប្រជាពលរដ្ឋទូទៅ និងប្រជាពលរដ្ឋងាយរងគ្រោះ ជាពិសេសដែលចង់បង្ហាញពីកង្វល់របស់ពួកគេដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ ជាពិសេសតាមរយៈវេទិកាឌីជីថល។

**គោលដៅ ៣.២.២** ចំនួននៃប្រជាពលរដ្ឋដែលបានចូលរួមក្នុងសកម្មភាពដែលដឹកនាំដោយ API បានរាយការណ៍ពីអារម្មណ៍ទទួលបានសិទ្ធិអំណាច និងបញ្ចេញមតិរបស់ពួកគេជាសាធារណៈបន្ទាប់ពីការចូលរួមក្នុងសកម្មភាពរបស់ API ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងអភិវឌ្ឍសមត្ថភាពរបស់សកម្មជន (ស្ត្រី ៥០%) ដើម្បីនិយាយជាសាធារណៈតាមរយៈវេទិកាផ្សេងៗ។

ដោយរួមសហការជាមួយ ក្រុមការងារសិទ្ធិឌីជីថល(DRWG) API នឹងខិតខំប្រឹងប្រែងតស៊ូមតិរួមគ្នា និងកៀរគរធនធានលើការត្រួតពិនិត្យលើគោលនយោបាយនានា ដូចជា ការចាប់ពិរុទ្ធលើអ៊ីនធឺណិត ច្រកផ្លូវអ៊ីនធឺណិត ច្បាប់សន្តិសុខអ៊ីនធឺណិត ច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ច្បាប់ការពារទិន្នន័យផ្ទាល់ខ្លួន និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សាជាមួយអ្នកបង្កើតគោលនយោបាយ និងដៃគូអភិវឌ្ឍន៍។

API នឹងផលិតរបាយការណ៍ស្តីពីសេរីភាពនៃការបញ្ចេញមតិ និងសកម្មភាពដូចខាងក្រោម៖ (១) រៀបចំរបាយការណ៍ពិនិត្យជាសកលតាមកាលកំណត់ ហើយដាក់ជូនអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ (២) ធ្វើសេចក្តីរាយការណ៍ពីសេរីភាពនៃការបញ្ចេញមតិ និងការទទួលបានព័ត៌មាន។

**លទ្ធផល ៣.៣** ការលើកកម្ពស់សិទ្ធិអាជីវកម្ម

**គោលដៅ ៣.៣.១** យុវជន (ស្ត្រី ៥០%) ស្ត្រី និងអ្នកងាយរងគ្រោះ (ស្ត្រី ៥០%) យល់ថាសិទ្ធិការងាររបស់ពួកគេត្រូវបានគោរព។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងបង្កើតគំនិតផ្តួចផ្តើមសម្រាប់យុវជន ស្ត្រី និងអ្នកងាយរងគ្រោះ ដោយផ្តល់ឱកាសឱ្យពួកគេរៀនពីសិទ្ធិអាជីវកម្ម រួមទាំងកិច្ចគាំពារសង្គម និងទទួលបានជំនាញនៃការតស៊ូមតិសម្រាប់ការអនុវត្តសិទ្ធិអាជីវកម្មរបស់ពួកគេស្របតាមអនុសញ្ញា ILO ដែលកម្ពុជាជាភាគីសមាជិក។ API នឹងរៀបចំការជជែកដេញដោលយុវជនអំពីសិទ្ធិអាជីវកម្ម និងជួយពួកគេឱ្យចូលរួមយ៉ាងពេញលេញក្នុងការបង្កើតគោលនយោបាយ។ វគ្គសិក្សាភាពជាអ្នកដឹកនាំនឹងត្រូវបានផ្តល់ជូនដល់យុវជន ស្ត្រី និងអ្នកងាយរងគ្រោះ (លើជំនាញអាជីវកម្ម)។

**គោលដៅ ៣.៣.២** យុវជន (ស្ត្រី ៥០%) និងអ្នកងាយរងគ្រោះ (ស្ត្រី ៥០%) ទទួលបានកិច្ចគាំពារសង្គម។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងរៀបចំសិក្ខាសាលាសម្រាប់យុវជន ស្ត្រី ប្រជាពលរដ្ឋងាយរងគ្រោះ និងកម្មករអំពីសារៈសំខាន់នៃកិច្ចគាំពារសង្គម និងវិធីដើម្បីទទួលបានកិច្ចគាំពារសង្គម។ ស្របពេលជាមួយគ្នានេះដែរ API នឹងធ្វើការតស៊ូមតិជាមួយក្រសួងដើម្បីធ្វើឱ្យវិធានការនៃកិច្ចគាំពារសង្គមដែលមានស្រាប់កាន់តែមានបរិយាបន្ន ដោយការបំពេញចន្លោះនៅក្នុងការបែងចែកចំណាត់ថ្នាក់ប័ណ្ណសមធម៌ (IDPoor) ។

**លទ្ធផល ៣.៤** បញ្ហាប្រឈមរបស់កម្មករក្នុងវិស័យក្រៅប្រព័ន្ធ និងសហគ្រាសតូច និងមធ្យម ត្រូវបានស្វែងយល់ និងដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាល។

**គោលដៅ ៣.៤** កម្មករ (ស្ត្រី ៥០%) មានអារម្មណ៍ថាបញ្ហាប្រឈមរបស់ពួកគេត្រូវបានឈ្វេងយល់ និងលើកមកពិភាក្សាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលថ្នាក់ជាតិ។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងជួយគាំទ្រសម្រាប់ការតស៊ូមតិនិងគោលនយោបាយដែលមានឥទ្ធិពលជាមួយក្រសួងនិងធ្វើការជាមួយសហគ្រាសធុនមធ្យម និងធំ ដើម្បីអនុលោមតាមសិទ្ធិមនុស្ស សិទ្ធិបរិស្ថាន និងសិទ្ធិមនុស្សរបស់អាជីវកម្ម ដោយផ្អែកលើបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

API នឹងតស៊ូមតិសម្រាប់សិទ្ធិរបស់ប្រជាជនក្នុងការអប់រំ ជំនាញទន់ ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការងារសមរម្យ កិច្ចគាំពារសង្គម និងការដោះស្រាយបញ្ហាប្រឈមរបស់កម្មករក្នុងវិស័យក្រៅប្រព័ន្ធ និងសហគ្រាសធុនតូច និងមធ្យម (MSMEs)ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ។ ការយល់ដឹងអំពីហានិភ័យឌីជីថល បញ្ហាសុខភាព និងសុវត្ថិភាពការងារនឹងត្រូវដាក់បញ្ចូលក្នុងសកម្មភាព ដើម្បីបន្តការកាត់បន្ថយគ្រោះថ្នាក់សម្រាប់ស្ត្រីក្នុងការចូលរួមពាណិជ្ជកម្មជាតិ និងអន្តរជាតិ។

**គោលបំណងទី៤** សមត្ថភាពរបស់ API ត្រូវបានអភិវឌ្ឍបន្ថែមទៀត

កម្មវត្ថុនេះលើកឡើងពីបញ្ហាសមត្ថភាពរបស់ API ដើម្បីកែលម្អការងាររបស់ខ្លួនលើការតស៊ូមតិ និងកិច្ចសន្ទនាគោលនយោបាយ ដើម្បីសម្រេចបាននូវគោលបំណងទាំងបីខាងលើ។

**លទ្ធផល ៤.១** API ត្រូវបានគ្រប់គ្រង និងចាត់ចែងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធផល។

**គោលដៅ ៤.១** API គឺអនុលោមតាមស្តង់ដាអន្តរជាតិ និងតម្រូវការថវិការបស់ដៃគូអភិវឌ្ឍន៍។

### សកម្មភាពយុទ្ធសាស្ត្រ

API នឹងរៀបចំកិច្ចប្រជុំបុគ្គលិកទូទៅចំនួន ៤ ដងក្នុងមួយឆ្នាំ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិចំនួន ៦ ដងក្នុងមួយឆ្នាំ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ២ ដងក្នុងមួយឆ្នាំ។ គណៈកម្មាធិការប្រតិបត្តិ និង ក្រុមប្រឹក្សាភិបាល

របស់ API នឹងពិនិត្យ ហើយក្នុងករណីចាំបាច់[៧០] នឹងធ្វើបច្ចុប្បន្នភាពគោលនយោបាយរបស់អង្គការ ដើម្បីធានាដល់ម្ចាស់ជំនួយនូវឯកសារពាក់ព័ន្ធសម្រាប់ការវាយតម្លៃ សកម្មភាពដែលតម្រូវដោយរាជរដ្ឋាភិបាលនឹងត្រូវអនុវត្តតាមច្បាប់ផងដែរ។[៧១]

API នឹងពង្រឹងសមត្ថភាពរបស់ខ្លួនសម្រាប់ការគ្រប់គ្រងផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រកៀរគរមូលនិធិ និងទំនាក់ទំនង ព្រមទាំងប្រព័ន្ធត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សាផងដែរ។ ផែនការបណ្ដុះបណ្ដាលសមត្ថភាពបុគ្គលិកនឹងត្រូវបានបង្កើតឡើងនៅឆ្នាំ ២០២៤ និងអនុវត្តក្នុងឆ្នាំបន្តបន្ទាប់ទៀត។

**លទ្ធផល ៤.២** ការអភិវឌ្ឍសមត្ថភាព និងប្រឹក្សាយោបល់ របស់API ត្រូវបានបង្កើតឡើងជានីតិបុគ្គលដាច់ដោយឡែកជាសហគ្រាសសង្គម

**គោលដៅ៤.២** សហគ្រាសសង្គមមួយមានឈ្មោះថា "ការអភិវឌ្ឍសមត្ថភាព API" ត្រូវបានចុះបញ្ជីជាផ្លូវការជានីតិបុគ្គលដាច់ដោយឡែកនៅឆ្នាំ ២០២៥។

## សកម្មភាពយុទ្ធសាស្ត្រ

API នឹងរៀបចំបង្កើតសហគ្រាសសង្គមមួយដែលមានឈ្មោះថា "សេវាកម្មបណ្ដុះបណ្ដាល និងប្រឹក្សារបស់ API" ដើម្បីផ្ដល់ជូនសង្គមស៊ីវិល ដៃគូអភិវឌ្ឍ រដ្ឋាភិបាល វិស័យឯកជន នូវសេវាកម្មដ៏ល្អបំផុតដើម្បីបំពេញតម្រូវការ តាមរយៈការផ្ដល់សេវាកម្មបណ្ដុះបណ្ដាល និងប្រឹក្សាប្រកបដោយគុណភាពខ្ពស់។ សេវាកម្មទាំងនេះនឹងជួយជំរុញការផ្លាស់ប្ដូរសង្គម និងមានឥទ្ធិពលជាវិជ្ជមានដល់ប្រជាពលរដ្ឋងាយរងគ្រោះ និងជនក្រីក្រប្រកបដោយនិរន្តរភាព។

**លទ្ធផល ៤.៣** "សេវាកម្មបណ្ដុះបណ្ដាល និងប្រឹក្សារបស់ API" ផ្ដល់សេវាកម្មក្នុងវិស័យតស៊ូមតិ និងអភិបាលកិច្ចល្អ និងការអភិវឌ្ឍស្ថាប័ននៃអង្គការជាតិ និងអន្តរជាតិ សហគ្រាសធុនតូច និងមធ្យម ម្ចាស់ជំនួយ និងអង្គភាពរាជរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ។

**គោលដៅ ៤.៣** សេវាផ្ដល់ប្រឹក្សាក្នុងឆ្នាំ ២០២៤ - ២៨

## សកម្មភាពយុទ្ធសាស្ត្រ

"សេវាកម្មបណ្ដុះបណ្ដាល និងប្រឹក្សារបស់ API" នឹងដាក់សំណើសម្រាប់ការបណ្ដុះបណ្ដាល និងសេវាកម្មប្រឹក្សាដោយផ្អែកលើតម្រូវការរបស់អតិថិជន និងធ្វើការប្រកាសទៅកាន់ដៃគូអភិវឌ្ឍន៍សម្រាប់ការផ្ដល់មូលនិធិដល់សកម្មភាពរបស់ខ្លួន។ API នឹងរៀបចំបង្កើតសៀវភៅណែនាំបណ្ដុះបណ្ដាល កម្មវិធីសិក្សា និងវគ្គបណ្ដុះបណ្ដាលថ្មី និងធ្វើបច្ចុប្បន្នភាពវគ្គបណ្ដុះបណ្ដាលដែលមានស្រាប់លើសៀវភៅណែនាំបណ្ដុះបណ្ដាល និងកម្មវិធីសិក្សាទាំងអស់ដែល API បានបង្កើតនាពេលកន្លងមក។ អ្នកជំនាញដែលត្រូវការសម្រាប់កិច្ចការទាំងនេះនឹងត្រូវបានជ្រើសរើសពីក្រុមអ្នកបណ្ដុះបណ្ដាលគ្រូបង្គោល និងទីប្រឹក្សាដែលសហគ្រាសនឹងបង្កើត ដូចដែលនឹងបានបញ្ជាក់នៅក្នុងលក្ខខណ្ឌ។

## ៧ ការតាមដានត្រួតពិនិត្យ ការគ្រប់គ្រងទិន្នន័យ និងការរាយការណ៍

### ៧.១ ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ API ២០២៤-២៨

ផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈគម្រោងដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ ដែលមានតារាង: (សូចនាករ) សម្រាប់គម្រោងនីមួយៗក្នុងការត្រួតពិនិត្យ និងវាយតម្លៃ។

ជាទូទៅ ការស្ទង់មតិដើមគ្រានឹងត្រូវធ្វើឡើងមុនពេលចាប់ផ្តើមគម្រោងនីមួយៗ ហើយការស្ទង់មតិចុងក្រោយក៏នឹងត្រូវបានរៀបចំធ្វើឡើងផងដែរ។ ដូច្នេះហើយ គោលដៅសម្រាប់សូចនាករនីមួយៗនឹងត្រូវបានកំណត់បន្ទាប់ពីការស្ទង់មតិដើមគ្រា ដោយមិនឱ្យយឺតជាងឆ្នាំ ២០២៥។ លទ្ធផលទិន្នន័យស្ទង់មតិចុងក្រោយនឹងត្រូវបានវិភាគ និងផ្សព្វផ្សាយក្នុងចំណោមបុគ្គលិករបស់ API និងម្ចាស់ជំនួយសម្រាប់ការពិភាក្សាដើម្បីកំណត់អត្តសញ្ញាណជោគជ័យ និងបញ្ហាប្រឈម និងរបៀបដែលលទ្ធផលទាំងនោះត្រូវបានភ្ជាប់ទៅជំហានបន្ទាប់។

ឧបសម្ព័ន្ធទី២ បញ្ជាក់ព័ត៌មានលម្អិតលទ្ធផលនៃផែនការនេះ ជាមួយនឹងសូចនាករ គោលដៅពាក់ព័ន្ធ និងវិធីសាស្ត្រនៃការប្រមូលទិន្នន័យ និងការវិភាគ។ វាក៏ផ្តល់ការណែនាំពាក្យដែលបានប្រើប្រាស់ផងដែរ។

### ៧.២ ការគ្រប់គ្រងទិន្នន័យ

API បាននិងកំពុងរក្សាទុកនូវមូលដ្ឋានទិន្នន័យសម្រាប់ការត្រួតពិនិត្យ និងចំណេះដឹងពីការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ វាជាទំនួលខុសត្រូវរបស់អង្គភាព ត្រួតពិនិត្យតាមដាន និងវាយតម្លៃ/អ្នកជំនាញរបស់ API ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យមូលដ្ឋានជារៀងរាល់ត្រីមាស។ ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃអនឡាញនេះនឹងត្រូវប្រើប្រាស់ដើម្បីគាំទ្រដល់អង្គការសង្គមស៊ីវិលដែលត្រូវការដើម្បីជាផ្នែកមួយនៃការកសាងសមត្ថភាព និងការអភិវឌ្ឍស្ថាប័នសម្រាប់អង្គការសង្គមស៊ីវិល។

ព័ត៌មានលម្អិតនៃទិន្នន័យមូលដ្ឋាននេះត្រូវបានបង្ហាញនៅក្នុងផែនការប្រតិបត្តិការរបស់ API ។

### ៧.៣ ការធ្វើរបាយការណ៍

របាយការណ៍វឌ្ឍនភាពរបស់គម្រោងនឹងត្រូវបានបញ្ចប់ដោយមានការត្រួតពិនិត្យដោយនាយកប្រតិបត្តិ ហើយបន្ទាប់មកដាក់ជូនម្ចាស់ជំនួយតាមតម្រូវការរបស់ពួកគេ។

API នឹងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ (២០២៤- ២០២៨) រួមទាំងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅខាងលើ ជាមួយនឹងលទ្ធផលសិក្សាដែលសម្រេចបាន។ ក្នុងករណីដែល គម្រោងមិនទាន់ត្រូវបានបញ្ចប់ របាយការណ៍ពីដំណើរការអាចនឹងផ្អែកលើព័ត៌មានសង្ខេប ឬ ការពិភាក្សា ក្រុមពិភាក្សាជាមួយអ្នកចូលរួម។

## ៨ ការវិភាគហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ

| ហានិភ័យ | ផលប៉ះពាល់ | ប្រូបាបីលីតេ | កាត់បន្ថយហានិភ័យ |
|---|---|---|---|
| **បញ្ហានយោបាយ** | | | |
| ការចូលរួមកាន់តែតិចរបស់ពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការបង្ហាញពីកង្វល់របស់ពួកគេ។ | ការបង្កើនការលំបាកដល់ API ក្នុងការចូលរួមជាមួយប្រជាពលរដ្ឋ។ | ទាប - មធ្យម | API នឹង:<br>១ បន្តជំរុញកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង (ឧ. ក្រសួងមហាផ្ទៃ) និងស្ថាប័នពាក់ព័ន្ធ (ឧ.NCDD-S) សម្រាប់ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។<br>២ ពង្រឹងវិធានការកសាងទំនុកចិត្តជាមួយភាគីពាក់ព័ន្ធនៃរាជរដ្ឋាភិបាល។<br>៣ រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយសមាជិកអង្គការ សំខាន់ៗ (CCC, NGOF, CPDD, NEP) និងសង្គមស៊ីវិលផ្សេងទៀតក្នុងការលើកកម្ពស់ និងគាំទ្រការសន្ទនាដោយបើកចំហលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ។ |
| កង្វះតម្លាភាព គួបផ្សំជាមួយនឹងកម្រិតនៃការវិនិយោគពីបណ្តាប្រទេសក្នុងតំបន់អាស៊ីខ្ពស់ នឹងរួមចំណែកបង្កើនការលំបាកសម្រាប់ពលរដ្ឋក្នុងការ បញ្ចេញសំឡេងអំពីបញ្ហារបស់ពួកគេ។ | ការបង្កើនភាពលំបាកដល់ API ក្នុងការកៀរគរប្រជាពលរដ្ឋឱ្យចូលរួម។ | ទាប - មធ្យម | |
| **បញ្ហាហិរញ្ញវត្ថុ** | | | |
| ការកាត់បន្ថយការផ្តល់ហិរញ្ញប្បទានអន្តរជាតិ ដោយសារការកែទម្រង់មិនបានល្អគ្រប់គ្រាន់ផ្នែកអភិបាលកិច្ចប្រជាធិបតេយ្យរបស់កម្ពុជា។<br>ការថយចុះថវិកាដោយសារ (១) ជម្លោះអន្តរជាតិ (ឧ. នៅមជ្ឈិមបូព៌ា និងអ៊ុយក្រែន) និង (២) លទ្ធផលបោះឆ្នោតដែលផ្លាស់ប្តូរអាទិភាពថវិកាជាតិនៅអឺរ៉ុប និងសហរដ្ឋអាមេរិក។ | កាត់បន្ថយការផ្តល់មូលនិធិសម្រាប់សកម្មភាពយុទ្ធសាស្ត្ររបស់ API | មធ្យម | ១ កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនផ្សេងទៀត ដើម្បីកៀរគរមូលនិធិសម្រាប់សកម្មភាពអភិវឌ្ឍន៍។<br>២ ពង្រឹងសមត្ថភាពរបស់ API ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលមួយ សម្រាប់ការទទួលបានមូលនិធិដោយផ្ទាល់។<br>៣ ការបង្កើតសេវាកម្មបណ្តុះបណ្តាល និងប្រឹក្សារបស់ API។ |

## ឧបសម្ព័ន្ធទី១៖ ចំនួនអ្នកទទួលផលតាមភេទ និងគម្រោង ២០១៩ - ២៣

| គម្រោង | អ្នកទទួលផលសរុប | | | | ក្មេងក្រោមអាយុ 14ឆ្នាំ | យុវជន 15-30 | មនុស្សធំ 31-60 | មនុស្សចាស់លើស 60 | LGBTIQ | គ្រួសារអ្នកមានពិការ | គ្រួសារមានប័ណ្ណសមធម៌ | ជនជាតិដើមភាគតិច | អង្គការសហគមន៍ | អង្គការក្រៅរដ្ឋាភិបាល | រដ្ឋាភិបាល រដ្ឋសភា | វិស័យឯកជន | បណ្ដាញផ្សព្វផ្សាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | ផ្សេងៗ | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប |
| **ចំនួនសរុបមិនស្ទួន (មនុស្សម្នាក់ រាប់តែម្ដងគត់ ខណៈដែលគាត់បានចូលរួមសកម្មភាពច្រើនជាងមួយដង)។** | **203617** | **95298** | **108199** | **100** | **1751** | **51150** | **102503** | **5601** | **9** | **1059** | **10818** | **15054** | **47816** | **763** | **4010** | **58** | **31** | **114** |
| **គម្រោងទី១៖** សំឡេងប្រជាពលរដ្ឋ និងសកម្មភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា -BfdW-2020-2022 | 35744 | 19964 | 15780 | 0 | 334 | 651 | 33194 | 29 | 0 | 77 | 244 | 0 | 29030 | 13 | 833 | 0 | 6 | 0 |
| **គម្រោងទី២៖** ការពិភាក្សារបស់យុវជន ស្ដីពីការបង្កើតច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មានកម្ពុជា (2019-23) | 187 | 133 | 54 | 0 | 0 | 21 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **គម្រោងទី៣៖** ការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យមូលដ្ឋានក្នុងប្រទេសកម្ពុជា - បំណ្ណពិទ្ធពលរដ្ឋ (2018-20) | 8627 | 2956 | 5671 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **គម្រោងទី៤៖** ពង្រឹងយុវជនក្នុងការចូលរួមរៀបចំផែនការ និងថវិកាមូលដ្ឋាន (2020-21) | 1293 | 504 | 789 | 0 | 0 | 173 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **គម្រោងទី៥៖** ប្រកចេញចូលតែមួយសម្រាប់ប្រជាពលរដ្ឋ (2019-21) | 46877 | 22548 | 24329 | 0 | 0 | 22895 | 17226 | 1371 | 0 | 10 | 186 | 0 | 4 | 182 | 182 | 0 | 0 | 0 |
| **គម្រោងទី៦៖** កម្មវិធី Change theGameAcademy ក្នុងប្រទេសកម្ពុជា (2019-23) | 139 | 82 | 57 | 0 | 0 | 6 | 112 | 0 | 0 | 1 | 0 | 0 | 1 | 43 | 0 | 0 | 0 | 0 |
| **គម្រោងទី៧៖** សំឡេង និងសកម្មភាពជនមានពិការភាពនៅក្នុងគណនេយ្យភាពសង្គម I-SAF (2020-21) | 1323 | 822 | 501 | 0 | 0 | 6 | 112 | 0 | 0 | 1 | 0 | 0 | 1 | 43 | 0 | 0 | 0 | 0 |

| គម្រោង | អ្នកទទួលផលសរុប | | | | ក្មេងក្រោមអាយុ 14ឆ្នាំ | យុវជន 15-30 | មនុស្សធំ 31-60 | មនុស្សចាស់លើស 60 | LGBTIQ | គ្រួសារអ្នកមានពិការ | គ្រួសារមានប័ណ្ណសមធម៌ | ជនជាតិដើមភាគតិច | អង្គការសហគមន៍ | អង្គការក្រៅរដ្ឋាភិបាល | រដ្ឋាភិបាល រដ្ឋសភា | វិស័យឯកជន | បណ្ដាញផ្សព្វផ្សាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | ផ្សេងៗ | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប | សរុប |
| **គម្រោងទី៨៖** ជំនួយមនុស្សធម៌ដល់ការផ្ទុះឡើងនៃជម្ងឺ កូវីដ 19xនិងវិបានការបិទខ្ទប់ក្នុងប្រទេសកម្ពុជា (ឆ្នាំ 2020) | 3639 | 1791 | 1848 | 0 | 0 | 0 | 3639 | 0 | 0 | 0 | 3639 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **គម្រោងទី៩៖** ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងយន្តការគណនេយ្យភាពសង្គមលើសេវាកិច្ចគាំពារសង្គម (2019-22) | 1733 | 772 | 961 | 0 | 0 | 14 | 71 | 34 | 0 | 0 | 44 | 0 | 0 | 0 | 9 | 0 | 0 | 0 |
| **គម្រោងទី១០៖** គាំទ្រដល់ការចូលរួមរបស់ពលរដ្ឋប្រកបដោយអត្ថន័យនិងគណនេយ្យភាពដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (2019-23) | 52771 | 18531 | 34240 | 0 | 0 | 20352 | 30551 | 1868 | 0 | 361 | 5838 | 13636 | 0 | 90 | 1338 | 0 | 0 | 0 |
| **គម្រោងទី១១៖** ការពង្រឹងសមត្ថភាពស្ថាប័ន និងប្រតិបត្តិការរបស់សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត (2019-21) | 21839 | 14390 | 7429 | 20 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **គម្រោងទី១២៖** សំឡេង និងសកម្មភាពរបស់ថ្នាក់ដឹកនាំយុវនារី និងសហគ្រិននារី(2019-23) | 355 | 188 | 147 | 0 | 0 | 320 | 366 | 0 | 0 | 0 | 0 | 0 | 0 | 8 | 163 | 0 | 0 | 0 |
| **គម្រោងទី១៣៖** គណនេយ្យភាពសង្គមប្រកបដោយភាពច្នៃប្រឌិតនៅកម្ពុជា ISAC (2019-24) | 6919 | 2519 | 4400 | 0 | 615 | 1791 | 3124 | 1397 | 9 | 60 | 384 | 15 | 0 | 0 | 759 | 0 | 0 | 0 |
| **គម្រោងទី១៤៖** សិទ្ធិទទួលបានព័ត៌មានសម្រាប់ទាំងអស់គ្នា (2019-23) | 3323 | 1329 | 1994 | 0 | 0 | 1493 | 655 | 44 | 0 | 44 | 66 | 1399 | 2050 | 54 | 200 | 1 | 0 | 0 |
| **គម្រោងទី១៥៖** គម្រោងសកម្មភាពត្រួតពិនិត្យការរឹតត្បិតសេរីភាពអ៊ីនធឺណិត (2022-24) | 471 | 252 | 139 | 80 | 0 | 52 | 347 | 15 | 0 | 0 | 0 | 0 | 0 | 58 | 0 | 0 | 0 | 80 |
| **គម្រោងទី១៦៖** ឆ្ពោះទៅរកតម្លាភាពលទ្ធកម្មសាធារណៈ | 132 | 92 | 40 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 16 | 0 |
| **គម្រោងទី១៧៖** សំឡេងបន្លឺឡើងកាន់តែខ្លាំងសម្រាប់កិច្ចគាំពារសង្គមតាមរយៈគណនេយ្យភាពសង្គម I-SAF (2022-23) | 1074 | 485 | 589 | 0 | 5 | 120 | 703 | 246 | 0 | 432 | 0 | 0 | 705 | 0 | 202 | 0 | 0 | 0 |
| **គម្រោងទី១៨៖** ការពង្រឹងសិទ្ធិអំណាចស្ត្រី និងយុវជនក្នុងភាពជាអ្នកដឹកនាំ (2023-24) | 440 | 250 | 190 | 0 | 0 | 133 | 307 | 0 | 0 | 0 | 0 | 0 | 60 | 229 | 7 | 0 | 5 | 0 |
| **គម្រោងទី១៩៖** សំឡេងសកម្មភាពប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ដំណាក់កាលទី២ (2023-25) | 709 | 479 | 230 | 0 | 0 | 56 | 607 | 46 | 0 | 0 | 0 | 1 | 168 | 266 | 148 | 2 | 4 | 20 |
| **គម្រោងទី២០៖** សំឡេងនិង សកម្មភាពប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា (2022-23) | 16022 | 7211 | 8811 | 0 | 797 | 3073 | 11601 | 551 | 0 | 74 | 417 | 3 | 15798 | 0 | 169 | 55 | 0 | 14 |

## ឧបសម្ព័ន្ធទី២៖ ក្របខ័ណ្ឌ ពិនិត្យ និងវាយតម្លៃ ២០២៤-២៨

តារាងខាងក្រោមបញ្ជាក់លម្អិតពីលទ្ធផលក្នុងសូចនាករ គោលដៅពាក់ព័ន្ធ វិធីសាស្ត្រនៃការប្រមូលទិន្នន័យ និងការវិភាគ។

ជួរទី ៣ កំណត់ពាក្យចាំបាច់បំផុតដែលបានប្រើ នឹងផ្តល់នូវការយល់ដឹងបន្ថែមក្នុងសូចនាករ ដែលចាំបាច់ត្រូវពិចារណាដើម្បីប្រមូលទិន្នន័យក្នុងបំណងត្រួតពិនិត្យ និងវាយតម្លៃ។

| (១) លទ្ធផល | (២) សូចនាករ | (៣) និយមន័យនៃពាក្យសំខាន់ៗ | (៤) តម្លៃគោលដៅសូចនាករ | (៥) វិធីសាស្ត្រប្រមូលទិន្នន័យ | (៦) វិធីសាស្ត្រនៃការវិភាគទិន្នន័យ | (៧) អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| **គោលបំណងទី១៖ ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចប្រជាធិបតេយ្យ និងគណនេយ្យភាព** | | | | | | |
| ១.១ រដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថភាពអនុវត្តមុខងារ (វិមជ្ឈការ) ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ | **១.១.១. ភាគរយនៃមន្ត្រីថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅបង្ហាញពីលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តមុខងារនិងតួនាទី។** | អាជ្ញាធរថ្នាក់ក្រោមជាតិ (SNAs) = ជារាជធានី ខេត្ត ស្រុក/ខណ្ឌ (DMK) ឃុំ/សង្កាត់<br>មន្ត្រីរាជការ = បុគ្គលិកនៅឯកន្លែងបញ្ជីបើកប្រាក់បៀវត្សរ៍របស់ឃុំ ស្រុក ខេត្ត ឬក្រសួង។<br>កាន់តែប្រសើរ = តាមការយល់ឃើញរបស់មន្ត្រី<br>មុខងាររបស់ពួកគេ = ដូចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១៨២ ១៨៣ និង ១៨៤ | នឹងធ្វើការកំណត់បន្ទាប់ពីធ្វើការស្ទង់មតិដើមគ្រា | ធ្វើការស្ទង់មតិ (ជាមួយ N> 20 ក្នុង ឃុំ ស្រុក និងខេត្ត)<br>សួរសំណួរអំពី៖<br>១ តើពួកគេអាចអនុវត្តមុខងាររបស់ពួកគេបានល្អប៉ុណ្ណា (៥-១) មាត្រដ្ឋានមុន និងក្រោយសកម្មភាពដឹកនាំ API<br>២ តើសកម្មភាពដឹកនាំ API បានរួមចំណែកដល់ការបង្កើនសមត្ថភាពបានកម្រិតណាដែរ?<br>ការធ្វើតេស្តមុន និងក្រោយវគ្គបណ្តុះបណ្តាលនីមួយៗដែលផ្តល់ដោយគម្រោងដឹកនាំ API | ចំនួននៃមន្ត្រីដែលបង្ហាញថាសកម្មភាពដែលដឹកនាំដោយ API បានបង្កើនសមត្ថភាព ក្នុងឃុំ ស្រុក ខេត្តរបស់ពួកគេ។<br>(ការធ្វើតេស្ត សម្រាប់រកភាពខុសគ្នាច្រើនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ) | អ្នកជំនាញតាមដាន និងវាយតម្លៃរបស់ API |

| (១)<br>លទ្ធផល | (២)<br>សូចនាករ | (៣)<br>និយមន័យនៃពាក្យសំខាន់ៗ | (៤)<br>តម្លៃគោលដៅសូចនាករ | (៥)<br>វិធីសាស្ត្រប្រមូលទិន្នន័យ | (៦)<br>វិធីសាស្ត្រនៃការវិភាគទិន្នន័យ | (៧)<br>អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ១.២ CBOs កំពុងត្រួតពិនិត្យមុខងារ និងសេវាវិមជ្ឈការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិអាទិភាពរបស់ប្រជាពលរដ្ឋជាពិសេសជនងាយរងគ្រោះ។ | **១.២.១. ចំនួន CBOs ដែលត្រួតពិនិត្យការអនុវត្ត SNAS បានធ្វើវិមជ្ឈការតាមមុខងារ និងសេវាកម្មរបស់ពួកគេ បន្ទាប់ពីទទួលបានការអភិវឌ្ឍសមត្ថភាពពី API។** | SNA៖ សូមមើលខាងលើ<br>មុខងារវិមជ្ឈការ៖ សូមមើលខាងលើ<br>ការត្រួតពិនិត្យ៖ សូមមើលខាងលើ | CBOs ចំនួន ១២០ | ការស្ទង់មតិដើមគ្រា ការស្ទង់មតិចុងក្រោយ ក្នុងចំណោម CBOs ដែលទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសមត្ថភាពរបស់ API | • គ្មាន = មិនបានពិនិត្យ<br>• ១ដង<br>• ២-៥ ដង<br>• >៦ដង | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធរបស់ API |
| ១.៣ ប្រជាពលរដ្ឋ (រួមទាំងអ្នកងាយរងគ្រោះ) ចូលរួមកាន់តែច្រើនក្នុងរដ្ឋបាលថ្នាក់ក្រោម ជាតិរបស់ពួកគេ។ | ១.៣.១. ចំនួនប្រជាពលរដ្ឋ (ចំនួនស្ត្រី) ដែលបានយល់ដឹងប្រសើរឡើងពីមុខងារ និងសេវាវិមជ្ឈការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>ភាគរយនៃការយល់ដឹងនេះចាំបាច់ត្រូវបំបែកដោយ ភាគរយនៃស្ត្រី និងក្មេងស្រី និង ភាគរយ នៃអ្នកងាយរងគ្រោះ។ | មុខងារ និងសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានពិពណ៌នានៅក្នុងអនុ-ក្រឹត្យលេខ ១៨២ ១៨៣ និង ១៨៤ របស់រដ្ឋាភិបាល និងសៀវភៅណែនាំស្តីពីការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ(ក្រសួងមហាផ្ទៃ ខែមីនា ឆ្នាំ២០២១)។<br>ការយល់ដឹងកាន់តែប្រសើរឡើងក្នុងភាគរយ នៃចម្លើយត្រឹមត្រូវនៅក្នុងការធ្វើតេស្តសាកល្បងមុន និងក្រោយវគ្គសិក្សា។ | នឹងធ្វើការកំណត់បន្ទាប់ពីធ្វើការស្ទង់មតិដើមគ្រា | ការធ្វើតេស្តសាកល្បងមុននិងក្រោយវគ្គសិក្សារបស់ API លើសកម្មភាពបណ្តុះបណ្តាលសមត្ថភាពនឹងបង្ហាញពីការកើនឡើងនៃការយល់ដឹង។ | ការកើនឡើងនៃយល់ដឹងនឹងត្រូវបានចាត់ថ្នាក់ជា៖<br>• តិចតួចបំផុត៖ កើនឡើង ១០% នៅក្នុងចម្លើយត្រឹមត្រូវ។<br>• តិចតួច៖ ១១-៤០% កើនឡើងនៅក្នុងចម្លើយត្រឹមត្រូវ។<br>• មធ្យម៖ ៤១% - ៧០% កើនឡើងក្នុងចម្លើយត្រឹមត្រូវ។<br>• ខ្ពស់៖ កើនឡើង ៧១% ក្នុងចម្លើយត្រឹមត្រូវ។ | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API |
| | **១.៣.២. ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋដែល ត្រូវបានពង្រឹងដោយសកម្មភាពដែលដឹកនាំដោយ API កំពុងត្រួតពិនិត្យសេវាកម្មដែលផ្តល់ជូនពួកគេ និងក្រុមគ្រួសារ សាច់ញាតិ និង** | សេវាកម្ម៖ សូមមើលខាងលើ។<br>ការពង្រឹងការយល់ដឹង៖ ទទួលបានពិន្ទុខ្ពស់តិចតួចលើសូចនាករ ១.២.១ ការត្រួតពិនិត្យដែលបានពិនិត្យយ៉ាងហោចណាស់ម្តងលើគុណភាពនៃសេវាកម្ម (ឧ. ល្បឿននៃ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋដែល ត្រូវបានពង្រឹង។<br>នឹងធ្វើការកំណត់បន្ទាប់ពីការស្ទង់មតិមូលដ្ឋាន។ | ការធ្វើតេស្តមុន និងក្រោយវគ្គបណ្តុះបណ្តាលនីមួយៗដែលផ្តល់ដោយគម្រោងដឹកនាំ API។<br>ចំណោមប្រជាពលរដ្ឋស្ទង់មតិពីការយល់ដឹងដែលត្រូវបានពង្រឹងដោយ API ឬដៃគូនៅក្នុងគម្រោងដឹកនាំ API ។ | តារាងប្រេកង់៖<br>• គ្មាន = មិនបានពិនិត្យ<br>• ម្តង<br>• ២-៥ ដង<br>• ៦ ដង | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធរបស់ API ។ |

| (១)<br>លទ្ធផល | (២)<br>សូចនាករ | (៣)<br>និយមន័យនៃពាក្យសំខាន់ៗ | (៤)<br>តម្លៃគោលដៅសូចនាករ | (៥)<br>វិធីសាស្រ្តប្រមូលទិន្នន័យ | (៦)<br>វិធីសាស្រ្តនៃការវិភាគទិន្នន័យ | (៧)<br>អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | មិត្តភក្តិរបស់ពួកគេ)និងមុខងារផ្សេងទៀតរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ។<br>ភាគរយនេះនឹងត្រូវបំបែកដោយចំនួនភាគរយ នៃស្ត្រី និងក្មេងស្រី និងចំនួនភាគរយ នៃអ្នកងាយរងគ្រោះភាគច្រើន។ | ដឹកជញ្ជូនមានភាពត្រឹមត្រូវ ការចំណាយ អាកប្បកិរិយារបស់មន្ត្រី និង ទិដ្ឋភាពផ្សេងទៀតដែលបានបញ្ជាក់ក្នុងអំឡុងពេលកសាងសមត្ថភាព) និងបានរាយការណ៍អំពីរបកគំហើញទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឬបុគ្គលដែលរាយការណ៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. CAF) | | | | |
| | ១.៣.៣. ចំនួនស្រុកដែលការសន្ទនាស្ថាបនារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ និងឬ អង្គការសហគមន៍ CBOs កំពុងដំណើរការ។ | ក្នុងន័យស្ថាបនា = ពិភាក្សាដោយបើកចំហនូវដំណោះស្រាយដែលអាចកើតមានលើបញ្ហាប្រឈម។ បានរាយការណ៍ (ទោះបីជាមិនមានមូលនិធិសម្រាប់ការអនុវត្តដំណោះស្រាយទាំងនោះក៏ដោយ)<br>កំពុងបន្ត = បានចាប់ផ្តើមបន្ទាប់ពីការអភិវឌ្ឍសមត្ថភាពដោយ API | ចំនួន ៣០ ស្រុក | ការស្ទង់មតិមូលដ្ឋាន និងស្ទង់មតិចុងក្រោយក្នុងចំណោមCBOsដែលទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍សមត្ថភាពរបស់ API ។ | បង្ហាញជាចំនួនស្រុក (និងភាគរយនៃស្រុកគោលដៅទាំងអស់ ដែល API ដឹកនាំសកម្មភាព ។ | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធរបស់ API ។ |
| | ១.៣.៤. ចំនួនយុវជន ស្ត្រី និងប្រជាពលរដ្ឋងាយរងគ្រោះ ដែលចូលរួមក្នុងការធ្វើសេចក្តីសម្រេច/ការធ្វើផែនការនៅក្នុងឃុំ/សង្កាត់របស់ពួកគេ។ | យុវជនទាំងប្រុសទាំងស្រី អាយុចន្លោះ ពី ១៤ ឆ្នាំ ដល់ ៣០ឆ្នាំ (តាមនិយមន័យក្រសួងអប់រំយុវជននិង កីឡា) | នឹងធ្វើការកំណត់បន្ទាប់ពីធ្វើការស្ទង់មតិដើមគ្រា។ | ការស្ទង់មតិដើមគ្រា និងស្ទង់មតិចុងក្រោយក្នុងចំណោមយុវជន ស្ត្រី និងអ្នកងាយរងគ្រោះដែលទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសមត្ថភាពរបស់ API។ | | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធរបស់ API ។ |

| (១) លទ្ធផល | (២) សូចនាករ | (៣) និយមន័យនៃពាក្យសំខាន់ៗ | (៤) តម្លៃគោលដៅសូចនាករ | (៥) វិធីសាស្ត្រប្រមូលទិន្នន័យ | (៦) វិធីសាស្ត្រនៃការវិភាគទិន្នន័យ | (៧) អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ១.៥ ការបង្កើនទំនុកចិត្តនិងការពេញចិត្តរបស់ប្រជាពលរដ្ឋលើរចនាសម្ព័ន្ធផ្តល់សេវារបស់ SNAS ។ | **១.៥.១. ចំនួនប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅធ្វើការសង្កេតឃើញមានភាពប្រសើរឡើងនៅក្នុងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចដែលមានពិន្ទុបានលេចឡើងពីការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ និងការសន្ទនាទល់មុខគ្នា។**<br>ភាគរយនេះនឹងត្រូវបានបំបែកដោយចំនួនភាគរយនៃស្ត្រីនិងកុមារីនិងភាគរយ នៃប្រជាជនដែលងាយរងគ្រោះ។ | ប័ណ្ណពិន្ទុពលរដ្ឋ=ដូចដែលបានរៀបចំនៅក្រោមគម្រោង API ពីមុន។ | នឹងធ្វើការកំណត់បន្ទាប់ពីធ្វើការស្ទង់មតិមូលដ្ឋាន។ | របាយការណ៍ពីការសន្ទនានិងកាតពិន្ទុ។ | ទិន្នន័យដែលបានវិភាគ តាមឃុំនិងស្រុក (និង តាមខេត្ត )។ | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធរបស់ API ។ |
| **គោលបំណងទី២៖ ការអភិវឌ្ឍ ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយ និងច្បាប់សាធារណៈ មានលក្ខណៈបរិយាបន្ន និងប្រជាធិបតេយ្យ។** | | | | | | |
| ២.១ សំឡេងរបស់ជនងាយរងគ្រោះពីសហគមន៍និងយុវជនមកពីសាកលវិទ្យាល័យវិទ្យាល័យ ត្រូវបានទទួលស្គាល់ និងលើកឡើងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ | **២.១.១ ចំនួនប្រជាពលរដ្ឋភាគច្រើនដែលទទួលបានចំណេះដឹងអំពីគ្រប់គ្រងធនធានធម្មជាតិ បរិស្ថានប្រកបដោយនិរន្តរភាពនិងបម្រែបម្រួលអាកាសធាតុ**<br>ភាគរយនេះនឹងត្រូវបានបំបែកដោយចំនួនភាគរយ នៃស្ត្រី និងកុមារី និងភាគរយនៃប្រជាជនដែលងាយរងគ្រោះ។ | ធនធានធម្មជាតិ = (ជាទូទៅ៖ សត្វ បន្លែ ប្រេងឥន្ទនៈ ខ្យល់ ទឹក រ៉ែ និងដី។ ផែនការនេះនឹង ផ្តោតលើព្រៃឈើ ការនេសាទ ទឹក និងដី។ | នឹងធ្វើការកំណត់បន្ទាប់ពីធ្វើការស្ទង់មតិមូលដ្ឋាន។ | ការធ្វើតេស្តមុន និងក្រោយវគ្គបណ្តុះបណ្តាលនីមួយៗដែលផ្តល់ដោយគម្រោងដឹកនាំ API។ | ការកើនឡើងនៃយល់ដឹងនឹងត្រូវបានចាត់ថ្នាក់ជា៖<br>• តិចតួចបំផុត៖ កើនឡើង 10% នៅក្នុងចម្លើយត្រឹមត្រូវ។<br>• តិចតួច៖ ១១-៤០%<br>• មធ្យម៖ ៤១-៧០% កើនឡើងនៅក្នុងចម្លើយត្រឹមត្រូវ។<br>• ខ្ពស់៖ ៧១% | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយ ក្រុមការងារពាក់ព័ន្ធ API |

| (១)<br>លទ្ធផល | (២)<br>សូចនាករ | (៣)<br>និយមន័យនៃពាក្យសំខាន់ៗ | (៤)<br>តម្លៃគោលដៅសូចនាករ | (៥)<br>វិធីសាស្ត្រប្រមូលទិន្នន័យ | (៦)<br>វិធីសាស្ត្រនៃការវិភាគទិន្នន័យ | (៧)<br>អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | ២.១.២.ចំនួនសហគមន៍ដែលរងផលប៉ះពាល់ដោយបញ្ហា NRM និងបម្រែបម្រួលអាកាសធាតុដែលប្រជាពលរដ្ឋងាយរងគ្រោះកំពុងពិនិត្យ និងការពារធនធានធម្មជាតិរបស់សហគមន៍របស់ពួកគេ និងលើកឡើងពីកង្វល់របស់ពួកគេនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | រងផលប៉ះពាល់ដោយ: សូមពិនិត្យមើលខាងលើ។<br>ផលប៉ះពាល់ដោយ = សមាជិកជាច្រើននៃសហគមន៍បង្ហាញក្នុងអំឡុងពេលការពិភាក្សាក្រុមមានអារម្មណ៍ថាសកម្មភាពរបស់មនុស្ស ឬអង្គការផ្សេងទៀតកំពុងមានផលប៉ះពាល់អវិជ្ជមានលើធនធានរបស់ពួកគេ។ | ចំនួន ៥០ សហគមន៍ | ការស្ទង់មតិមូលដ្ឋាន និងការស្ទង់មតិចុងក្រោយក្នុងចំណោមយុវជន ស្ត្រី និងអ្នកជួបការលំបាកដែលទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសមត្ថភាពរបស់ API។ | | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយក្រុមការងារពាក់ព័ន្ធ API ។ |
| ២.២ ការស្រាវជ្រាវ និងភស្តុតាងបន្ថែមទៀតដែលអាចរកបានសម្រាប់ការសន្ទនាគោលនយោបាយ និងការត្រួតពិនិត្យការអនុវត្ត។ | **២.២.១.ចំនួននៃការស្រាវជ្រាវ/ការសិក្សាដែលបានបញ្ចប់ និងផ្សព្វផ្សាយរបកគំហើញ។** | ការផ្សព្វផ្សាយ=របាយការណ៍ជាសំណេរ និង ផ្ទាល់មាត់ទៅកាន់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្សព្វផ្សាយ។ | ចំនួន១០ ការសិក្សា។ | | | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយក្រុមការងារពាក់ព័ន្ធ API |
| ២.៣ CBOs និង CSO ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ អាចជួយប្រជាពលរដ្ឋចូលរួមទាមទារឱ្យរដ្ឋាភិបាលក្នុងការទទួលខុសត្រូវរបស់ពួកគេ សម្រាប់ការអនុវត្តច្បាប់ និងគោលនយោបាយរបស់ខ្លួន។ | ២.៣.១. ចំនួន សមាជិក CBOs និង CSO នៃអង្គការA2IWG, CPDD, BWG, DRWG, SP4ALL, CCC, NGO Forum, បណ្ដាញ CSOs នៅតាមខេត្តគឺទាមទារឱ្យមានការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលកណ្ដាល។ | ច្បាប់ និងគោលនយោបាយ = ទាក់ទងនឹង សិទ្ធិទទួលព័ត៌មាន និងសិទ្ធិឌីជីថល, D&D, កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម។ | ចំនួន CBOs១២០ និងការស្ទង់មតិក្នុងចំណោម CSOs ចំនួន ២០០។ | ការស្ទង់មតិក្នុងចំណោម | | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយក្រុមការងារពាក់ព័ន្ធAPI |

| (១) លទ្ធផល | (២) សូចនាករ | (៣) និយមន័យនៃពាក្យសំខាន់ៗ | (៤) តម្លៃគោលដៅសូចនាករ | (៥) វិធីសាស្ត្រប្រមូលទិន្នន័យ | (៦) វិធីសាស្ត្រនៃការវិភាគទិន្នន័យ | (៧) អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| **កម្មវត្ថុទី៣៖ សិទ្ធិមនុស្សទទួលបានគោរព ការពារ និងបំពេញបន្ថែម។** | | | | | | |
| ៣.១ ទទួលស្គាល់សិទ្ធិទទួលបានព័ត៌មាន | **៣.១.១. ច្បាប់ A2I ត្រូវបានអនុម័តយល់ព្រម (ជាមួយនឹងធាតុចូលដែលទទួលបានពី CSOs) នឹងការអនុវត្តនៅគ្រប់កម្រិតទាំងអស់ (ត្រឹមឆ្នាំ ២០២៨) ។** | អនុម័ត = ផ្សព្វផ្សាយតាមសារព័ត៌មានជាតិ។ | ត្រូវបានអនុម័តនៅឆ្នាំ ២០២៨ | សារព័ត៌មានជាតិ | | |
| | **៣.១.២. ចំនួនស្រុកដែលបង្ហាញព័ត៌មានយ៉ាងសកម្មទៅប្រជាពលរដ្ឋ។** | ការបង្ហាញព័ត៌មានសកម្ម = ស្នើសុំដោយប្រជាពលរដ្ឋ ប្រជាពលរដ្ឋ និង/ឬ CBOs របស់ពួកគេ។ | ចំនួន ៣០ ស្រុក | សម្ភាសជាមួយចៅហ្វាយក្រុង និងស្រុកដែល ឆ្លងកាត់ការត្រួតពិនិត្យ វិនិច្ឆ័យព័ត៌មានពី CBOs (សូមមើលលទ្ធផល ២.៣)។ | ការរាប់សំណាក ពីស្រុកដែលស្របតាមលក្ខខណ្ឌ។ | អ្នកជំនាញពិនិត្យ និងវាយតម្លៃរបស់ API គាំទ្រដោយក្រុមការងារពាក់ព័ន្ធAPI |
| | ៣.១.៣. ចំនួនក្រសួងដែលជាសមាជិកនៃគណៈកម្មាធិការជាតិ គ.ជ.អ.ប. បានបង្ហាញព័ត៌មានសកម្មស្របតាមបទប្បញ្ញត្តិដែលមានស្រាប់។ | | ចំនួន ២០ ក្រសួង | បទសម្ភាសន៍ជាមួយ គ.ជ.អ.ប និងក្រសួងពាក់ព័ន្ធ។ | | |
| ៣.២ សេរីភាពនៃការបញ្ចេញមតិត្រូវបានគោរព និងអនុវត្ត។ | **៣.២.១.ភាគរយនៃប្រជាពលរដ្ឋដែលបានចូលរួមក្នុងសកម្មភាពដឹកនាំ API មានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការបញ្ចេញមតិ**<br>ភាគរយនេះនឹងត្រូវបានបំបែកដោយចំនួនភាគរយ នៃស្ត្រី និងកុមារី និងភាគរយនៃប្រជាជនដែលងាយរងគ្រោះ។ | មានអារម្មណ៍ថាមានសុវត្ថិភាព = យោងទៅតាមការយល់ឃើញរបស់ពួកគេផ្ទាល់ដែលបានបង្ហាញក្នុងអំឡុងពេលសម្ភាសន៍ | ត្រូវបានកំណត់-បន្ទាប់ពីការស្ទង់មតិមូលដ្ឋាន ។ | ស្ទង់មតិប្រជាពលរដ្ឋក្នុងចំណោមអ្នកដែលបានចូលរួមក្នុងសកម្មភាពដឹកនាំ API (N> ២០ ក្នុងមួយស្រុក) | ការរាប់ចំនួនប្រជាពលរដ្ឋដែលបានចូលរួមក្នុង សកម្មភាពដែលដឹកនាំ ដោយ API ។ | |

